**មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលឡើមលើកទី១៩

# យន្តការបន្ថារទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃព្រហស្បតិ៍ ទី២០ ខែធ្នូ ឆ្នាំ២០០៦**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខប់សែល ដំណាក់កាលទី ២**
COPCEL Phase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**
**United Nations Development Programme (UNDP)**

**របៀបវារៈ**

១.ការពិនិត្យនិងអនុម័តនូវកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹម លើកទី១៨ ដែលបានធ្វើឡើងកាលពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០០៦។

២.ការចែករំលែកព័ត៌មានទូទៅជុំវិញការរៀបចំការបោះឆ្នោត-របាយការណ៍ស្តីពីខប់សែលប្រ៉មក្រុងកែប

៣.យុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់-ជំពូកទី៨ ទាំងមូលនៃបទបញ្ជានិងនីតិវិធី (ទំព័រទី៩០ ដល់ ១០៨)

៤.សេចក្តីផ្សេងៗ

---

## ១. ការពិនិត្យនិងអនុម័តនូវកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹម លើកទី១៨ ដែលបានធ្វើឡើងកាលពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០០៦

**លោក ឳក សេរី សោភ័ក្ត្រ** បានធ្វើការថ្លែងនូវអំណរគុណចំពោះសមាជិកទាំងអស់ដែលបានធ្វើនូវការកែលំអរនូវកំណត់ហេតុនៃកិច្ចប្រជុំខប់សែលឡឹមលើកទី១៨ មកធ្វើការកែប្រែដើម្បីឱ្យមានភាពកាន់តែសុក្រិត្យបន្ថែមទៀត ។ លោក បានស្នើអង្គប្រជុំពិនិត្យមើលសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី ១៨ ដើម្បីអនុម័តមុននឹងធ្វើការផ្សព្វផ្សាយ ។ អង្គប្រជុំបានអនុម័តសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើក ទី១៨ យកជាផ្លូវការ ។

## ២. ការចែករំលែកព័ត៌មានទូទៅជុំវិញការរៀបចំការបោះឆ្នោត-របាយការណ៍ស្តីពីខប់សែលប្រ៉មក្រុងកែប និងខេត្តកោះកុង

**លោក ឳក សេរី សោភ័ក្ត្រ** បានរាយការណ៍ដោយកោតសរសើថានៅក្រុងកែប មានអ្នកចូលរួមជាច្រើននៅក្នុងកិច្ចប្រជុំខប់សែលប្រ៉មធ្វើនៅថ្ងៃទី ១១ ទោះចំថ្ងៃឈប់សំរាក ប៉ុន្តែពុំសូវមានទស្សនៈលើកឡើងច្រើនទេ ដោយសាថាលោក ប្រធាន PEC នៅក្រុងកែបបានធ្វើការបានល្អដោយមានធ្វើការជួបប្រជុំរាល់អាទិត្យនៅការិយាល័យ PEC ដូច្នេះបញ្ហាអ្វីៗដោះស្រាយអស់ ។ បញ្ហាដែលបានលើកឡើងនោះគ្រាន់តែជាការសុំសេចក្តីណែនាំ ជាអនុសាសន៍បន្តិចបន្តួចខ្លះទាក់ទងនិងរឿងបញ្ជីឈ្មោះ រឿងអត្តសញ្ញាណប័ណ្ណទាក់ទងទៅនិងនីតិវិធីបន្តិចបន្តួច ។ ក្រុមការងារខប់សែលរបស់វិទ្យាស្ថាន CDRI បានទៅប្រជុំចំនួន១៩ខេត្តហើយ នេះជាលើកទី១ហើយដែលឃើញខាងគណបក្សឯកឧត្តម សម រង្ស៊ី មិនមានលើកអ្វីទាល់តែសោះមិនដូចខេត្តឯទៀតៗឡើយ ។ នៅខេត្តកោះកុងក៏មានបញ្ហាច្រើនដែរ ដូចជាការចែកប័ណ្ណព័ត៌មានដោយសារនៅខេត្តកោះកុង នោះស្ថានភាពភូមិសាស្ត្រមិនអំណោយផលមានជិះកាណូត ហើយថវិកានោះគឺស្តួចស្តើងមិនអាចគ្រប់ដណ្តប់ទៅលើការចំណាយលើកប៉ាល់ កាណូត ដើម្បីចែកទៅដល់ស្រុកមួយៗនោះឡើយ ។ ខប់សែល គិតថាខេត្តនេះគួរតែបានទទួលការយកចិត្តទុកដាក់ពិសេស ។ ដោយភូមិសាស្ត្រមិនអំណោយផលនៅពេលប៉ូលិសចុះទៅធ្វើអត្តសញ្ញាណប័ណ្ណនោះពិបាក ដោយប្រជាពលរដ្ឋច្រើនតែទៅធ្វើរបរនេសាទបាត់ធ្វើឱ្យការចុះឈ្មោះក៏មិនបានច្រើនដូចខេត្តឯទៀតៗ ការធ្វើអត្តសញ្ញាណប័ណ្ណក៏ជួបនូវបញ្ហាច្រើន ។ នៅក្នុងខេត្តកោះកុង អង្គប្រជុំក៏បានលើកឡើងនូវបញ្ហាផ្សេងៗ ជុំវិញការចែកប័ណ្ណព័ត៌មានការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហើយមានការបារម្ភថា បើមាន ការខុសឈ្មោះច្រើនយ៉ាងនេះតើអាចទៅបោះឆ្នោតបានដែរ ឬ ទេ ? ហើយបញ្ហាអត្តសញ្ញាណប័ណ្ណដែលនៅខ្វះច្រើន ។ មានរឿងច្រើនដែលលើកឡើង ក៏ប៉ុន្តែចំលើយរបស់លោកស្នងការប៉ូលិស គឺសមរម្យណាស់ដោយឈរនៅលើឯកសារជាក់ច្បាស់រហូតទាល់តែដល់ខាងតំណាងគណបក្សជំទាស់ ឯកឧត្ត សម រង្ស៊ី លោកពេញចិត្ត និងចំលើយពីខាងអាជ្ញាធរ ។

## ៣.យុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់-ជំពូកទី៨ ទាំងមូលនៃបទបញ្ជានិងនីតិវិធី

**ឯកឧត្តម ទេព នីថា** អគ្គលេខាធិការរៀបចំជាតិការបោះឆ្នោត បានធ្វើការរាយការណ៍ជូននូវសកម្មភាពដែល គជប បានធ្វើនិងកំពុងធ្វើ និងបន្តធ្វើនៅពេលចំពោះមុខនេះ ។ ទី១ លទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ នៅក្នុងការប្តឹងតវ៉ា និងការដោះ

ស្រាយបណ្តឹងនៅក្នុងដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានបញ្ចប់ហើយ ប៉ុន្តែអ្វីដែល គជប កំពុងតែបន្តធ្វើនោះ គឺបញ្ចូលទិន្នន័យនៃឈ្មោះអ្នកដែលត្រូវបានចុះឈ្មោះថ្មី អ្នកដែលត្រូវលុបឈ្មោះចេញនិងអ្នកដែលកែតំរូវឈ្មោះនៅក្នុងប្រព័ន្ធកំព្យូទ័រ ។ រហូតមក ដល់ដើមសប្តាហ៏នេះការបញ្ចូលឈ្មោះត្រូវបានបញ្ចប់ហើយ គឺ គជប បញ្ចូលឈ្មោះអ្នកចុះឈ្មោះថ្មីបានចំនួន ១២៨៤៩៨១ នាក់ ហើយលុបឈ្មោះប្រជាពលរដ្ឋដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតដែលត្រូវផ្លាស់ប្តូរទីលំនៅ ស្លាប់ ឬក៏ត្រូវបានដកហូតសិទ្ធបោះឆ្នោត តាមរយៈការប្តឹងតវ៉ា ឬក៏មានទោសផ្សេងៗទៅតាមច្បាប់នោះបានជាង ១៦០០០០នាក់ ។ តួលេខជាតួលេខបណ្តោះអាសន្ន ព្រោះថារហូតដល់ថ្ងៃ៣១ខែធ្នូទើបបាន គជប ផ្តល់សុពលភាព ។ ឈ្មោះដែលត្រូវកែមាន ២,០៤៣,៣៦០ នាក់ ហើយរហូតមកដល់ពេលនេះកែបានរហូតដល់ទៅ៦៧ភាគរយ គឺកែបានប្រហែលជាង ១៤០០០០០នាក់ ។ ទាក់ទងនិងលេខទាំងអស់នេះ បើពិនិត្យទៅតាមការិយាល័យដែលផ្តល់ឱ្យនៅមុនពេលចុះឈ្មោះបោះឆ្នោតនោះគឺ គជប ប៉ាន់ស្មានបង្កើតការិយាល័យថ្មី មួយចំនួននិងបូករួមការិយាល័យចាស់គឺផ្តល់ការិយាល័យសំរាប់ឃុំសង្កាត់ធ្វើការចុះឈ្មោះនោះមានតែ ១៤១៩០ ការិយាល័យទេ ប៉ុន្តែតាមរយៈការចុះ ឈ្មោះជាក់ស្តែងនិងការបញ្ចូលទិន្នន័យនេះទៅការិយាល័យទាំងអស់នោះបានកើនឡើងរហូតដល់ ១៤៤៣៣ ការិយាល័យ ក្នុងនោះមានការិយាល័យភ្លោះប្រមាណជាង ២៩១ ការិយាល័យ ហើយការិយាល័យភ្លោះនេះសូមជំរាបថា លេខការិយាល័យនៅដដែលទេ ទីតាំងការិយាល័យនៅពីរជាប់គ្នាតែម្តង គ្រាន់តែបញ្ជីឈ្មោះបោះឆ្នោតហែកចេញជាពីរហើយការិយាល័យរៀបចំជាពីរដាច់គ្នា ប្រជាពលរដ្ឋដែលទៅបោះឆ្នោតក៏មិនមានការលំបាកដែរ បើសិនជាមិនឃើញបញ្ជីខាងនេះ គឺមានបញ្ជីនៅខាងមួយទៀត ។ ឧទាហរណ៏ បើសិនថ្នាក់រៀនគឺថ្នាក់ពីរជាប់គ្នា ហើយការិយាល័យបោះឆ្នោតនិមួយៗ គឺមានមន្ត្រីម្នាក់នៅខាងក្រៅការិយាល័យដើម្បីជំរាបជូនគាត់ អំពីឈ្មោះគាត់នៅក្នុងការិយាល័យ ហើយជាពិសេសមុនពេលបោះឆ្នោត គជប នឹងផ្តល់ជូននូវប័ណ្ណព័តិមានអ្នកបោះឆ្នោតថែមទៀត ដើម្បីឱ្យគាត់ងាយស្រួលរកឈ្មោះនៅក្នុងការិយាល័យ ដើម្បីបោះឆ្នោត។

ចំពោះបញ្ហាថាខុសឈ្មោះច្រើនបោះឆ្នោតបានដែរឬទេ? ហើយគ្មានទំរង់១០១៨បោះឆ្នោតបានឬទេ? ធ្វើទាន់ឬមិនទាន់? បញ្ហានេះបើមើលតាមលេខដែលកែ ២ លាននាក់ជាងនេះ ប្រៀបធៀបនិងប័ណ្ណបោះឆ្នោតដែលផ្តល់ឱ្យពីមុននោះ គឺប្រហាក់ប្រហែល ហើយប្រជាពលរដ្ឋដែលទៅកែឈ្មោះនោះគឺគាត់មានអត្តសញ្ញាណប័ណ្ណ ឬឯកសារសំរាប់ទៅបោះឆ្នោតហើយ បានគាត់ទៅកែឈ្មោះ គាត់នៅក្នុងបញ្ជីបោះឆ្នោតព្រោះបើគាត់មិនមានឯកសារជាផ្លូវការមួយដែលគាត់យកថ្មីទេ គាត់មិនអាចទៅកែឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតបានទេ ។ ចំពោះទំរង់១០១៨នេះ គជប បានជូនដំណឹងទៅឃុំសង្កាត់ហើយ ដើម្បីឱ្យរំលឹកជូនប្រជាពលរដ្ឋដែលគាត់បានសុំចុះឈ្មោះបោះឆ្នោត សុំ ១០១៨ មិនទាន់បិទរូបថតនោះ ដើម្បីឱ្យយករូបថតមកបិទទៅជួបមេឃុំដើម្បីបិទរូបថតនិងបោះត្រានៅលើរូបថតនេះនៅលើទំរង់ ១០១៨ ដើម្បីប្រើប្រាស់បោះឆ្នោត ហើយទំរង់នេះគឺចាប់ធ្វើតាំងពីថ្ងៃដែលជូនដំណឹងរហូតដល់មុនថ្ងៃបោះឆ្នោត ។ ករណី១០១៨ នេះ គជប មាន ភាពតឹងរឹងខ្លះចំពោះប្រជាពលរដ្ឋដែលទៅសុំ១០១៨ថ្មី ទាមទារឱ្យមានសាក្សី២នាក់ទៅតាមលក្ខខ័ណ្ឌ ហើយទាមទារយករូបថតភ្លាម ដោយមិនឱ្យជឿទៀតទេ ព្រោះត្រូវប្រើប្រាស់នៅក្នុងពេលបោះឆ្នោត ហើយបញ្ហានេះ គជប នឹងណែនាំបន្ថែមទៀតនៅក្នុងវគ្គសិក្សាដែល គជប កំពុងតែធ្វើការបណ្តុះបណ្តាល ហើយពីមុនដែល គជប មិនទាន់ធ្វើការផ្សព្វផ្សាយពីការយក ១០១៨ មកបញ្ជាក់នេះដោយសារតែបញ្ជីបោះឆ្នោត ពុំទាន់បានផ្តល់សុពលភាព ការបញ្ជាក់របស់មេឃុំ ចៅសង្កាត់ ក៏មិនមានមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់ដើម្បីនិងបញ្ជាក់ជូនទេ ។ នៅឃុំ សង្កាត់នោះគឺមានតែបញ្ជីចុងក្រោយដែលបញ្ជូនចេញពី គជប ទៅ ហើយមានគូសលុប និងមានបញ្ជីសរសេរដោយដៃមួយ ហើយបញ្ជីនេះមិនទាន់ផ្តល់សុពលភាពទេ ទោះបីជានៅលើមូលដ្ឋានអនុវត្តជាក់ស្តែង គ្មានអ្នកប្តឹងតវ៉ា បញ្ជីនោះអាចជាបញ្ជីផ្លូវការក៏ដោយ តែការផ្តល់សុពលភាពរបស់ គជប ជាផ្លូវការនោះមិនទាន់មានទេ ។

ចំនុចទី២ ការបើកវគ្គបណ្តុះបណ្តាលរបស់ គជប ។ ឥឡូវនេះ គជប ធ្វើការបណ្តុះបណ្តាលនៅក្នុងដំណាក់កាលចុះបញ្ជីបេក្ខជននិងការឃោសនាបោះឆ្នោតហើយនៅក្នុងផែនការណ៏មេរបស់ គជប គឺធ្វើការបណ្តុះបណ្តាលគ្រូពី គជប ទៅហើយចុះទៅបណ្តុះបណ្តាលគ្រូនៅតាមខេត្តក្រុង ហើយគ្រូនៅតាមខេត្តក្រុងចុះបណ្តុះបណ្តាលនៅតាមទីប្រមូលផ្តុំនៅតាមស្រុកខ័ណ្ឌ ។ ក៏ប៉ុន្តែដោយការពិនិត្យឃើញជាក់ស្តែង គជប ចង់ឱ្យគ្រូនៅតាម

ខេត្តក្រុងមករៀននៅជាតិ ។ ដូចនេះ គជប ប្តូរផែនការណ៍នេះវិញឥឡូវអញ្ជើញគ្រូនៅតាមខេត្តក្រុងទាំងអស់រួមទាំងសមាជិកគណៈកម្មាធិការខេត្ត រៀបចំការបោះឆ្នោតមួយខេត្ត២នាក់ដើម្បីមកធ្វើការបណ្តុះបណ្តាលនៅភ្នំពេញ ហើយនឹងធ្វើនៅថ្ងៃទី២០-២១ ខែធ្នូនេះ ហើយការបណ្តុះបណ្តាលនៅថ្នាក់ជាតិនេះ រួមទាំងមន្ត្រីបោះឆ្នោតនៅថ្នាក់ខេត្តផង រួមទាំងគណបក្សនយោបាយ និងអង្គការសង្កេតការណ៍ បោះឆ្នោតផង ដែលមានចំនួនរហូតដល់ប្រហែល ២៧០ នាក់ ។ គ្រូដែលទទួលការបណ្តុះបណ្តាលនេះហើយគាត់នឹងចុះទៅខេត្តវិញ ហើយគាត់ធ្វើកាបណ្តុះបណ្តាលមន្ត្រីថ្នាក់បោះឆ្នោតថ្នាក់ខេត្តដែលមិនបានមករៀននោះរួមជាមួយតំណាងគណបក្សនៅថ្នាក់ខេត្ត និងអ្នកសង្កេតកាណ៍នៅថ្នាក់ខេត្ត សរុបគ្រប់ ខេត្តទាំងអស់មានអ្នកចូលរៀនប្រហែល ៨៦៥ នាក់គឺបើកនៅថ្នាក់ខេត្តដោយឡែក១ពីគ្នាហើយក្រោយពីបណ្តុះបណ្តាលនៅថ្នាក់ខេត្តនេះហើយគ្រូនៅ ថ្នាក់ខេត្តនេះនឹងធ្វើការបណ្តុះបណ្តាលបន្តទៅទៀតនៅថ្នាក់ឃុំសង្កាត់មិនមែនតាមឃុំសង្កាត់ទេ គឺប្រមូលផ្តុំ ។ គ្រូទាំង អស់ គជប រើសតាមស្រុកដោយមួយស្រុកម្នាក់រួមមាន ១៨៦ នាក់ហើយនឹងចុះបណ្តុះបណ្តាលនៅតាមស្រុកដោយម្នាក់១ទទួលមួយស្រុក ហើយអាចបើកតែមួយវគ្គ បើឃុំសង្កាត់ តិចនៅក្នុងស្រុកនោះ តែបើមានឃុំសង្កាត់ច្រើននៅក្នុងស្រុកនោះគឺនឹងធ្វើការបណ្តុះបណ្តាល២វគ្គ ហើយនឹងធ្វើនៅក្នុងរង្វង់ថ្ងៃ២៥ទៅថ្ងៃ ២៩ ។ សំរាប់ការរៀបចំសំរាប់វគ្គទាំងអស់នេះគឺមានឯកសារពីការឃោសនាបោះឆ្នោត និងឯកសារណែនាំពីការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយមានបន្ថែមឯកសារមួយចំនួនទៀតដែលទាក់ទងនឹងការចែកប័ណ្ណព័តិមាន អ្នកបោះឆ្នោត ដែលគំរោងនឹងធ្វើពីថ្ងៃទី៨កុម្ភៈដល់៨មិនា ។

ចំនុចទី៣ អំពីការត្រៀមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។ ជាទូទៅ គជប បានជូនព័តិមានទូលំទូលាយដល់គណបក្សនយោបាយតាមរយៈការប្រជុំរបស់ គជប ក៏ដូចជាលិខិតស្នាម ហើយបានជូនឯកសារដែលទាក់ទងនិងការចុះបញ្ជីនេះដល់គណបក្សនយោបាយទាំងអស់ជាក្រដាសថតចំលងជូនទាំង CD ដែលមានកម្មវិធីទាក់ទងនិងទំរង់សំរាប់ការចុះបញ្ជីនេះជូនទៅអស់ហើយ ។ ហើយគណបក្សនយោបាយអាចប្រើប្រាស់ឯកសារនេះថតចំលងបំពេញដើម្បីយកទៅចុះបញ្ជីនៅឃុំសង្កាត់ក៏បាន ហើយទី២ អាចទៅសុំឯកសារនេះនៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតក៏បានព្រោះ គជប ក៏បញ្ជូនឯកសារទាំងអស់នេះទៅឃុំសង្កាត់តែម្តងព្រោះអាចឯកសារមួយចំនួនគណបក្សបំពេញពីថ្នាក់លើទៅហើយឯកសារមួយចំនួនទៀតនៅបំពេញនៅថ្នាក់ក្រោម ។ ឯកសារនេះ គជប បានចែកជូនទាំង២ហើយ គឺទី១ជូនពី គជប ទៅ ហើយទី២ជូននៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតតែម្តង ហើយឯកសារនេះជូនដោយឥតគិតថ្លៃ ។ ការទទួលការចុះបញ្ជីនេះ គជប ធ្វើការបណ្តុះ បណ្តាលនៅក្នុងពេលខាងមុខនេះ បើតាមការប្រមើលមើលអាចមានបញ្ហាខ្លះសំរាប់គណបក្សនយោបាយ ហើយ គជប សូមជូនដំណឹងនៅពេលនេះ ដើម្បីឱ្យគណបក្សនយោបាយត្រៀម គឺ ទី១ បញ្ហាបេក្ខជនព្រោះរហូតមកដល់ពេលនេះមានបញ្ហាខ្លះហើយ ទាក់ទងទៅនិងការបញ្ជាក់ឈ្មោះបេក្ខជននៅលើបញ្ជីបោះឆ្នោត នៅមានឃុំសង្កាត់ខ្លះដែលមេឃុំពុំបានបំពេញការងារនេះបានល្អ ហើយម្យ៉ាងដោយសារការខ្វះទំនាក់ទំនងល្អរវាងគ្នាដែរ ហើយ គជប បានអន្តរាគមន៍ទៅ២-៣ខេត្តហើយ ដូចជាខេត្តព្រះវិហារ ខេត្តតាកែវ ក្រុងភ្នំពេញ ហើយករណីផ្សេង១គ្នា ឧទាហរណ៍ដូចជាខេត្ត ព្រះវិហារនោះការបញ្ជាក់មេឃុំមានការយឺតយ៉ាវ ហើយគាត់ពុំដឹងពីតួនាទីរបស់គាត់ច្បាស់ ហើយ គជប បានជូនព័តិមានទៅ ហើយដើម្បីឱ្យ គណៈកម្មាធិការខេត្តសំរបសំរួលបញ្ហានេះ ។ ទី២ នៅខេត្តតាកែវដោយមេឃុំនោះគាត់ទៅលេងនៅសៀមរាបគាត់អវត្តមានប៉ុន្មានថ្ងៃ ហើយ គណបក្សទៅរកចុះបញ្ជីអត់ជួបក៏រាយការណ៍មក ហើយ គជប បានជូនដំណឹងទៅខេត្តដើម្បីសំរួលការងារនេះ ហើយមិនយឺតយូរអីទេ ។ ដោយឡែក នៅក្នុងក្រុងភ្នំពេញមានសង្កាត់ខ្លះពុំបានចុះបញ្ជាក់ឱ្យទេ ដោយសារមានបញ្ហាខ្លះកើត ឡើងដោយការខ្វះទំនាក់ទំនងមានការមិនចុះសំរុងពាក្យសំដីគ្នា ខ្លះហើយបញ្ហានេះ គជប ក៏សំរបសំរួលដែរ ។

ទាក់ទងនិងបញ្ជីបេក្ខជននេះដែរសំរាប់គណបក្សនយោបាយនៅមូលដ្ឋានមានការប្រទាញប្រទង់បេក្ខជនគ្នាច្រើនដូចនេះ គណបក្សនយោបាយនិមួយ១គួរយកចិត្តទុកដាក់ ដាក់បេក្ខជនរបស់ខ្លួនឱ្យបានច្រើន តាមច្បាប់ថាយ៉ាងតិចក៏មួយជាពីរ គឺពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់បើអាចដាក់បានលើសហ្នឹងទៀតក៏ជាការល្អ ព្រោះថានៅក្នុងដំណាក់កាលនៃការចុះបញ្ជីបេក្ខជននេះអាចមានការប្រទាញប្រទង់ខ្លះអាចមានអ្នកខ្លះឈរ ២ គណបក្សរួចបើតាមច្បាប់បើសិនជាមនុស្សម្នាក់ក្នុងពេលតែមួយគាត់អាចមានសិទ្ធនៅក្នុងគណបក្សតែមួយទេ តែបើគាត់មាន ២ គេយកពេលវេលា

ចុងក្រោយដែលអ្នកនោះនៅក្នុងគណបក្សណាមួយនោះជាផ្លូវការដូច្នេះជៀសវាងបញ្ហានេះគឺថាគណបក្សគួរតែដាក់បេក្ខជនឱ្យ បានច្រើនព្រោះនៅក្នុងដំណាក់កាលដាក់បញ្ជី៧ថ្ងៃ ហើយនិងការពិនិត្យ១ថ្ងៃ ហើយនិងការកែតំរូវប៉ុន្មានថ្ងៃ គណបក្សគួរតែដាក់បេក្ខជនឱ្យបាន ច្រើនព្រោះបើមានការដកបេក្ខជនណាមួយចេញដោយសារគាត់សុំលាលែង ឬក៏ដោយសារបញ្ហាគាត់នៅ២គណបក្សក៏មាននៅសល់បេក្ខជននៅគ្រប់តាមចំនួនកំណត់នៃច្បាប់ដែរ ការសំរេចនៅថ្នាក់ឃុំនៅក្នុងដំណាក់កាលទី១នេះ ប្រសិនបើបេក្ខជន ឬលក្ខ័ខ័ណ្ឌទាំងអស់ហ្នឹងមិនគ្រប់ទៅ តាមច្បាប់ទេ គឺគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតបដិសេធតែម្តងហើយគាត់អាចប្តឹងតវ៉ារហូតដល់ថ្នាក់ខេត្ត និង គជប ។ តែបើសិនជាក្រោយពីបិទបញ្ជីបេក្ខជនតំបូងហើយ ប្រសិនបើមានបញ្ហា មានការប្តឹងតវ៉ា អាចប្តឹងមកដល់ គជប ហើយ គជប អាចសំរេចលុបតែឈ្មោះអ្នកណាមិន គ្រប់គ្រាន់ទេ ប៉ុន្តែដំណាក់កាលទី១ គឺបដិសេធពាក្យការសុំចុះបញ្ជីតែម្តង ។

បញ្ហាទី៤ ទាក់ទងនិងបញ្ហាសន្តិសុខសំរាប់ការបោះឆ្នោត បើប្រៀបធៀបនិងការបោះឆ្នោតមុនៗ មានភាពខុសគ្នាខ្លះនិងដូចគ្នាខ្លះ ។ ទី១បើប្រៀបធៀបការបោះឆ្នោតកាលឆ្នាំ១៩៩៨ ឃើញថាខុសរចនាសម្ព័ន្ធនៃគណៈកម្មាធិការទទួលខាងសន្តិសុខមួយចំនួន ហើយបើបៀបធៀបនិងឆ្នាំ២០០២ គឺប្រហាក់ប្រហែលគ្នាហើយ ២០០៣ ក៏ប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែខុសគ្នានិងការបោះឆ្នោតព្រឹទ្ធសភា ។ ការបោះឆ្នោតព្រឹទ្ធសភាខាងសន្តិសុខនេះមិនបង្កើតការិយាល័យសន្តិសុខថ្នាក់ជាតិទេ គឺក្រសួងណែនាំផ្ទាល់ទៅគណៈបញ្ជាការឯកភាពនៅថ្នាក់ខេត្តតែសំរាប់ការបោះឆ្នោតសកលធំៗនេះគឺបង្កើតការិយាល័យសន្តិសុខកណ្តាលមួយដែលមានសមាសភាពខាងក្រសួងមហាផ្ទៃ និងខាងក្រសួងការពារជាតិហើយណែនាំទៅគណៈបញ្ជារការឯកភាពនៅថ្នាក់ខេត្ត ដោយឡែក គជប ទាំង៩រូបទទួលការងារសន្តិសុខ ហើយដោយមានអគ្គលេខាធិការដ្ឋានជា សេនាធិការហើយនៅថ្នាក់ខេត្ត គជប ឱ្យគណៈកម្មាធិការខេត្តក្រុងបំពេញការងារនេះដោយសហការជាមួយគណៈបញ្ជារការឯកភាព នៅថ្នាក់ខេត្ត ហើយដោយរចនាសម្ព័ន្ធ គជប មិនមានថ្នាក់ស្រុកទេ ដូចនេះថ្នាក់ខេត្តរបស់ គជប ធ្វើការជាមួយថ្នាក់ខេត្តនៃអាជ្ញាធរផង ធ្វើការជាមួយថ្នាក់ស្រុកនៃអាជ្ញាធរផង ហើយដោយឡែកនៅថ្នាក់ឃុំគឺគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតធ្វើការជាមួយថ្នាក់ឃុំ ។ ដោយការបោះឆ្នោតឃុំសង្កាត់ការងារសន្តិសុខនៅថ្នាក់ឃុំសង្កាត់នេះគឺប្រគល់ឱ្យនរគរបាលប៉ុស្តិ៍តែម្តង គឺមិនមែនក្រុមប្រឹក្សាឃុំសង្កាត់ទេ ដោយក្រុម ប្រឹក្សាឃុំសង្កាត់គាត់ជាបេក្ខជនគាត់ជាប់ធ្វើការងារបោះឆ្នោតរបស់គាត់ ។ គណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោត ធ្វើការសហការជាមួយប៉ូលិសប៉ុស្តិ៍ធ្វើ ការការពារសន្តិសុខនៅថ្នាក់ឃុំសង្កាត់រហូតដល់ការិយាល័យបោះឆ្នោត។

ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គជប ចែកលើកទី២នេះគ្រាន់តែជាការជូនព័ត៌មានដល់ប្រជាពលរដ្ឋ អញ្ជើញគាត់ទៅបោះឆ្នោតនៅ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ នេះ ។ នៅក្នុងនោះ គជប ដាក់ឈ្មោះរបស់គាត់ ដាក់ទិន្ន័យដែលពាក់ព័ន្ធនិងគាត់ ហើយអ្វីដែលសំខាន់នោះគឺថ្ងៃបោះឆ្នោតពេលវេលាបោះឆ្នោតទីតាំងការិយាល័យបោះឆ្នោតដែលគាត់ត្រូវទៅបោះឆ្នោត ។ ប័ណ្ណព័ត៌មានអ្នក បោះឆ្នោតនេះគឺមិនអាចប្រើប្រាស់ទៅបោះឆ្នោតបានទេក៏ប៉ុន្តែគាត់អាចកាន់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះទៅការិយាល័យបោះឆ្នោតដោយភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ដើម្បីយកឯកសារនេះទៅ យកទៅឱ្យអ្នកដែលជួយរកឈ្មោះឱ្យគាត់ងាយនិងរកឈ្មោះគាត់នៅលើបញ្ជីបោះឆ្នោត ដូចនេះប័ណ្ណព័ត៌មានអ្នក បោះឆ្នោតទោះបីគាត់បានទទួលឬមិនបានទទួលឱ្យតែគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតគាត់ ទៅបោះឆ្នោតគាត់មានអត្តសញ្ញាណប័ណ្ណ ដើម្បីទៅបោះឆ្នោតគាត់អាចទៅបោះឆ្នោតបានដោយគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។ ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ ដោយ គជប ធ្លាប់ដកពិសោធន៍នៅក្នុងការចែកប័ណ្ណព័ត៌មាននៅមុនការចុះឈ្មោះបោះឆ្នោត លើកនេះគឺនិងបង្កើតក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅថ្នាក់ឃុំសង្កាត់គឺមានគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតជាប្រធាន ហើយមានសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ម្នាក់ជាសមាជិក ហើយមានមេភូមិដែលទាក់ទងនិងភូមិរបស់គាត់ជាសមាជិកនិងមានអង្គការមិនមែនរដ្ឋាភិបាលម្នាក់ទៀតចូលរួមជាសមាជិក ហើយចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងការចែកប័ណ្ណព័ត៌មាននេះគឺ គជប មិនមែនជាអ្នកជ្រើសរើសទេ គឺ UNDP ដែលគាត់ជាអ្នកឧបត្ថម្ភ នៅលើការងារនេះគាត់នឹងជ្រើសរើសអង្គការមិនមែនរដ្ឋាភិបាលដែលស្ម័គ្រចិត្តធ្វើការជាមួយគាត់នោះ ដើម្បីចូលរួមធ្វើការចែកប័ណ្ណព័ត៌មាននេះ ។ ហើយការចែកប័ណ្ណព័ត៌មាននេះនឹងធ្វើការចែក

ពីថ្ងៃទី០៨ ខែកុម្ភៈដល់០៨ខែមិនា ហើយបើសិនប័ណ្ណព័ត៌មាននេះមាននៅសល់គឺយកទៅរក្សាទុកនៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការ បោះឆ្នោត ហើយប្រជាពលរដ្ឋអាចអញ្ជើញទៅយកប័ណ្ណព័ត៌មាននេះនៅគណៈកម្មាធិការឃុំសង្កាត់រៀប ចំការបោះឆ្នោតចាប់ពីដើមខែមិនា ទៅក្រោយពីការចែកប័ណ្ណរហូតទៅដល់មុនថ្ងៃបោះឆ្នោត ។ បញ្ហាសំខាន់២នេះ ក្រសួងមហាផ្ទៃនឹង ធ្វើការប្រកាសជាផ្លូវការទាំងការងារសន្តិសុខទាំងការងារចែកប័ណ្ណព័ត៌មានធ្វើការប្រកាសជាផ្លូវការនៅក្រសួងមហាផ្ទៃនៅថ្ងៃទី ២៧ ខែធ្នូ នេះដោយមានអញ្ជើញគ្រប់ស្ថាប័នដែលពាក់ព័ន្ធជាពិសេសអាជ្ញាធរខេត្តអភិបាលអភិបាលរងខេត្តដែលត្រូវមកប្រជុំនៅក្រសួងមហាផ្ទៃដើម្បីធ្វើការ ប្រកាសពីការងារសន្តិសុខបោះឆ្នោត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតហើយប្រហែលជានៅក្នុងថ្ងៃ២៧នេះដែរ នឹងមានការប្រកាសថែមទៀតអំពីការណែនាំរំលឹកដល់អាជ្ញាធរមូលដ្ឋានដើម្បីបង្កលក្ខណៈឱ្យគណបក្សនយោបាយបំពេញការងារតាមច្បាប់ស្តីពីគណបក្សនយោបាយក្នុងការចូលរួមនៅក្នុងការបោះឆ្នោតហើយការពិតទៅការងារនេះគ្រាន់តែរំលឹកទេ ព្រោះមាននៅក្នុងច្បាប់ ហើយកន្លងមកគណបក្សក៏បានធ្វើ សកម្មភាពហើយ គជបគ្រាន់តែរំលឹកឱ្យមានការយកចិត្តទុកដាក់ថែមទៀតទាំងអាជ្ញាធរ ទាំងគណបក្សនយោបាយ ដើម្បីបំពេញការងាររបស់ខ្លួន ឱ្យស្របតាមច្បាប់ ។

ចំពោះការងារដែលត្រូវធ្វើចំពោះមុខបន្ថែមទៀតនេះគឺទី១ គជប នឹងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតថ្ងៃទី៣១ខែធ្នូនេះហើយផុតពីនឹងទៅ គជប នឹងផលិតប័ណ្ណព័ត៌មាន ។ ហើយប័ណ្ណព័ត៌មាននេះ លេខឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតអាចឡើងទៅដល់ជាង ៧លាន៨សែន បើប្រៀបធៀបទៅឆ្នាំ២០០៥គឺ ៦លាន៧សែន ហើយឥឡូវឡើងជាង១លាន ហើយនៅក្នុងការផលិតនេះក៏ត្រូវប្រើពេលវេលាយូរដែរ ។ គជប កំពុងត្រៀមការងារបន្ថែមទៀតគឺ ការឃោសនាបោះឆ្នោត ហើយការឃោសនាបោះឆ្នោតខ្ញុំនឹងជំរាបជូននៅពេលក្រោយមាន ចំនុចអីខ្លះដែលត្រូវយកចិត្តទុកដាក់ ។

**លោក ឧក សេរី សោភក្តិ៍** លើកថា គជប ធ្វើនេះនឹងរឹតតែធ្វើឱ្យមានតម្លាភាពថែមទៀត ហើយនេះជាការដកស្រង់ មេរៀនដែលបានរៀនសូត្រអំពីកាលពីខែសីហាកន្លងទៅ កំហុសខុសឆ្គងទាំងប៉ុន្មាន ហើយបានដឹងស្រាប់ហើយថា ខប់សែលទាំងនៅថ្នាក់ជាតិ នៅថ្នាក់ខេត្តក្តីបានជូននូវអនុសាសន៏ច្រើនណាស់ ហើយជាពិសេសទាក់ទងទៅនិងសមាជិកម្នាក់របស់គណៈកម្មាធិការដែលមកពីអង្គការក្រៅរដ្ឋាភិបាល ។ លោក ផ្ទាល់បានធ្វើការនេះជាមួយខាង UNDP ដើម្បីធ្វើយ៉ាងណាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីជំរុញឱ្យមាន លក្ខណៈបើកទ្វាចំហរហើយមានតម្លាភាពឱ្យខ្លាំង។

**លោកវិរៈសេនីយ៏ឯក ផេង សុនហេង** លោកបានរាយការណ៏ពីលទ្ធផលនៃការផ្តល់អត្តសញ្ញាណប័ណ្ណ និងហេតុផលខ្លះៗដែលការធ្វើអត្តសញ្ញាណប័ណ្ណរបស់នគរបាលជាតិ ។ គិតមកដល់ថ្ងៃទី១០ខែធ្នូឆ្នាំ២០០៦នេះ គឺចំនួនប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណ ប័ណ្ណមានចំនួន ៧៣៤៨៩៣៤ នាក់ គឺបានបំពេញបែបបទរួចបានចំនួន ៦៩៣២៤៨៣ សន្លឹក ។ ការផលិតគឺបានផលិតរួចចំនួន ៦៤២៩៤២០ សន្លឹក ។ ការចុះហត្ថលេខារបស់អាជ្ញាធរខេត្តរួចមានចំនួន ៦២០៤៧៣៦ សន្លឹក និងបានចែកជូន ប្រជាពលរដ្ឋប្រើប្រាស់បានចំនួន ៦១២៦៩៨៣ សន្លឹកដូច្នេះកិច្ចការនេះគិតជាភាគរយបានចំនួន ៩២ ភាគរយ ហើយនៅទូទាំងប្រទេសនៅសល់តែ៨ភាគរយទៀតទេ ។ ក្រសួងមហាផ្ទៃអគ្គស្នងការនគរបាលជាតិ គឺបានបើកយុទ្ធនាការណ៏ធ្វើអត្តសញ្ញាណប័ណ្ណនេះដោយយកចុងខែធ្នូនេះដើម្បីបំពេញការងារឱ្យបាន ប៉ុន្តែមកទល់និងពេលនេះឃើញថានៅមានចំនួនអ្នកធ្វើសេសសល់ ហេតុផលដែលនៅសេសសល់នេះគឺមានកត្តាជាច្រើនដែលសំខាន់គឺ កត្តារបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋកន្លងមកនេះដោយការអនុវត្តទៅឃើញថាការដែលទៅធ្វើមិនបានល្អនេះ គឺដោយសារការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋដែលគាត់ទៅប្រកបរបររកស៊ីរហូតដល់ប្រទេសក្រៅក៏មានគាត់មិនទាន់បានវិលត្រឡប់មកផ្ទះ មានការផ្លាស់ប្តូរទីលំនៅពីខេត្ត មួយទៅខេត្តមួយ បញ្ហាចាស់ជរា ដូច្នោះអ្នកខ្លះចាស់ជរារហូតដល់អាយុ៨០-៩០ទៅគាត់មិនអាចធ្វើដំណើរមក បំពេញបែបបទបានទេ គឺគាត់នៅតែផ្ទះ ហើយខាងស្ថានីយ៏ចល័តប៉ុន្តែមិនអាចលើកទៅដាក់ទៅថតនៅផ្ទះគាត់បានទេ ដូច្នេះបញ្ហានេះក៏មានមួយចំនួនដែរ ហើយអ្នកខ្លះក៏មានជំងឺរ៉ាំរៃមកព្យាបាលនៅមន្ទីពេទ្យឆ្ងាយៗ ហើយមិនទាន់វិលត្រឡប់ទៅផ្ទះក៏ជាបញ្ហាមួយដែរ ។ មានអ្នកខ្លះទៅបួស ដល់ពេលទៅធ្វើស្ថិតិនៅក្នុងបញ្ជីគឺគ្រប់អាយុហើយ ប៉ុន្តែគាត់ទៅបួសបាត់ទៅក៏មានដែរ អ្នកខ្លះក៏វិកលចរិក ដូច្នេះបញ្ហាទាំងអស់នេះ ទោះបីជាក្រសួងមហាផ្ទៃធ្វើមិនទាន់បាន១០០ភាគរយ ក៏ប៉ុន្តែក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិនៅតែខិតខំ

ប្រឹងប្រែងជានិច្ចរហូត ទាល់តែដល់ថ្ងៃបោះឆ្នោតគឺត្រូវធ្វើឱ្យទាន់ជូនដល់ប្រជាពលរដ្ឋឱ្យបានប៉ុន្មានតាមលទ្ធភាពគឺប្រឹងប្រែងរហូត ហើយនៅចុងខែមករា នេះក្រសួង មហាផ្ទៃនិងអគ្គស្នងការដ្ឋាននរគលបាលជាតិប្រហែលជាធ្វើសន្និបាតមួយបូកសរុបនូវការងារផ្តល់អត្តសញ្ញាណប័ណ្ណនេះដើម្បីរកឱ្យឃើញនូវការលំ បាកនិងការងាយស្រួលយ៉ាងម៉េច ហើយចំនួនពិតប្រាកដដែលមិនទាន់ធ្វើជូនដល់ប្រជាពលរដ្ឋនោះ គឺនឹងធ្វើយ៉ាងណានៅចុងខែមករានេះប្រហែលជា ក្រសួងមហាផ្ទៃនូវសន្និបាតនេះ ។

**លោក ឱក សេរី សោភ័ក្តិ៍** លើកឡើងថាចំពោះតួលេខ ៩២ ភាគរយនេះជាលទ្ធផលមួយធំធេងណាស់ហើយទោះជាយ៉ាងណាក៏ដូចជាខប់សែលបានទៅរៀបចំខប់សែលប្រ៉មនៅ១៩ខេត្តឃើញថាធ្វើមិនដល់ ១០០ ភាគរយដែរ ។ នេះដឹងច្បាស់ហើយដោយសារបញ្ហាចំណាកស្រុកដោយមូលហេតុសេដ្ឋកិច្ច ឬមួយដោយមូលហេតុដែលលោកវិរៈសេនីយ៍បានជំរាបជូននេះ ។ ក៏ប៉ុន្តែនៅពេលដែលទៅរៀបចំខប់សែលប្រ៉មនៅខេត្តទាំង ១៩ នោះ ឃើញថាប្រជាពលរដ្ឋបង្កើតនូវបញ្ហាច្រើនណាស់ហើយការបង្កើតបញ្ហានេះមិនមែនដោយចេតនាទេដោយសារផ្នត់គំនិតដែលចេញពីសង្គ្រាមមកការមិនបានយកចិត្តទុកដាក់ទៅលើលិខិតបទដ្ឋាន អត្រានុកូលដ្ឋាន ហើយដោយសារក្រុមប្រឹក្សាឃុំសង្កាត់ទើបនិងធ្វើការបាន ៤ ឆ្នាំទេដូច្នេះទំលាប់ថ្មីៗនៃការទៅចុះឈ្មោះនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ពេលកើត ពេលរៀបអាពាពិពាហ៍ ពេលស្លាប់ ហើយគាត់ដូរឈ្មោះច្រើនដងណាស់ ដូច្នេះទាំងបញ្ជីនៅកន្លែងនរគលបាលជាតិ នៅ គជប ក៏ដោយនៅក្នុងក្រុមប្រឹក្សា ឃុំសង្កាត់ ក៏ដោយ តែងតែមានស្ទួនច្រើន ។ លោកបានលើកថានៅក្នុងក្របខណ្ឌខប់សែល ការគ្រប់គ្រង ចំនួនប្រជាពលរដ្ឋមិនបានគឺជាបញ្ហារបស់ប្រទេសនិមួយៗមិនថាតែប្រទេសកម្ពុជាទេ ប្រទេសនៅក្នុងសកលលោកអ្នកណាក៏មានដែរហើយរាជរដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់ខ្ពស់នៅក្នុងបញ្ហាទាំងអស់នេះ ព្រោះបើគ្រប់គ្រងប្រជាពលរដ្ឋមិនបានទេបញ្ជីឈ្មោះបោះឆ្នោតអាចមានស្ទួនច្រើន ។ លោកលើកជាដំណោះស្រាយ មួយថាទៅថ្ងៃមុខទៅមាន វិធីតែមួយទេ ដូចប្រទេសជឿនលឿនបានធ្វើប៉ុន្តែនេះទាក់ទងទៅនិងបញ្ហាថវិការ គឺនរគលបាលជាតិគួរមានម៉ាស៊ីន Scanner ដែលផ្តិតរូបថត និងស្នាមមេដៃដែលមាននៅលើអត្តសញ្ញាណប័ណ្ណស្រាប់ហើយ បើមានពីរនាក់នោះត្រូវចេញបញ្ជីមួយច្បាស់លាស់ដើម្បីហៅសាម៉ីខ្លួនឱ្យជ្រើសរើស ឈ្មោះណាមួយពិតប្រាកដ ។

**ឯកឧត្តម អ៊ុក ភូរិ** ប្រធានគណបក្សប្រជាធិតេយ្យខ្មែរ លើកឡើងនូវចំនុច២ ដែលឯកឧត្តមបានចុះទៅដល់មូលដ្ឋាន ។ ឯកឧត្តម បានទូរស័ព្ទទៅជួបឯកឧត្តមអគ្គលេខាធិការ ទាក់ទងទៅនឹង គខប ខេត្តដើម្បីជួយសំរបសំរួលយ៉ាងណាឱ្យអភិបាលខេត្តជាពិសេសខេត្តព្រះវិហារដែលរហូតមកដល់ពេលនេះមិនព្រមទទួលស្គាល់វត្តមានរបស់គណបក្សប្រជាធិតេយ្យខ្មែរទោះជារូបខ្ញុំបានជូនពត៌មានរួចរាល់ហើយក៏ដោយ ។ តំណាងរបស់គណបក្សប្រជាធិតេយ្យខ្មែរបានទទួលសិទ្ធជូនចូលទៅជួបដល់ អភិបាលខេត្តផ្ទាល់ ប៉ុន្តែអភិបាលខេត្តលើកឡើងថា យកសំបុត្រមកឱ្យគាត់ខ្វះដីការអមគាត់មិនទទួល ។ គាត់យកដីការអមជាធំមិនព្រមយកលិខិត ហើយគាត់មិនអនុញ្ញាតិឱ្យ អភិបាលស្រុកទាំងមូលគឺស្រុករវៀងមិនឱ្យទទួលការចុះបញ្ជី ។ ឃើញថាអភិបាលខេត្តមានឥទ្ធិពលទៅលើអភិបាលស្រុក ហើយអភិបាលស្រុកសង្កត់ទៅលើមេឃុំមិនឱ្យទទួលការចុះបញ្ជីរបស់គណបក្សប្រជាធិតេយ្យខ្មែរចំនួន ៦ ឃុំនៅស្រុករវៀង ហើយរហូតមកដល់ពេលនេះ ស្រុក២បានទទួលហើយ ត្បែងមានជ័យ និងគូលេន ចំណែកស្រុករវៀងមិនព្រមទទួលដាច់ខាត ដូចនេះសូមឱ្យខាង គជប ជួយធ្វើអន្តាគមន៍នៅក្នុងចំនុចនេះដែរ ។

ចំនុចទី ២ ទាក់ទងនឹងមេឃុំជាច្រើនជាពិសេសនៅក្នុងខេត្តកណ្តាលទាំងមូលស្រាប់តែពេលនេះតំរូវឱ្យបេក្ខជនទាំងអស់ឱ្យទៅបង្ហាញខ្លួនម្តងម្នាក់ៗដើម្បីកែឈ្មោះដែលខុសទោះជាបង្ហាញបញ្ជីទាំងមូលដែលមានសាម៉ីខ្លួនព្រមបំពេញជីវប្រវត្តរបស់ខ្លួនមានត្រា របស់គណបក្សមានស្នាមផ្តិតមេដៃព្រមឈរឈ្មោះទៅហើយក៏ដោយ តែមេឃុំតំរូវសុំពិនិត្យរូប សុំពិនិត្យឈ្មោះ ហើយសុំឱ្យកែពេលនោះ ។ មកដល់ពេលនេះអ្នកឈរឈ្មោះទាំងឡាយរវល់ប្រមូលផល មិនអាចប្រមូលម្តងម្នាក់ៗឱ្យទៅបានទេ ដូច្នេះពីពេលនេះទៅដល់ ១០ ថ្ងៃ បើសិនជាធ្វើដូននេះតទៅទៀតគណបក្សនឹងមានគ្រោះដូចកាលឆ្នាំ២០០១-២០០២ទៀតហើយ ។ មេឃុំមិនគួរគប្បីយកបញ្ហាកែឈ្មោះយកទៅធ្វើដំណាលគ្នានិងសេចក្តីបញ្ជាក់របស់ខ្លួនទេ ។ មេឃុំគួរតែធ្វើបញ្ជាក់យោងទៅលើអ្នកនោះមានបញ្ជីចុះឈ្មោះនៅក្នុងឃុំ គោរពតាមលក្ខ័ខណ្ឌច្បាប់អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរមានលំនៅដ្ឋាននៅទីនោះមានប័ណ្ណពត៌មាន គឺគ្រប់គ្រាន់ ។

**លោក ម៉ា សុផល** តំណាងខាងខមហ្វ្រែលបានលើកឡើង ៤ចំនុចទាក់ទងនិងការសង្កេតទៅតាមដំណាក់កាលនៃការជ្រើសរើស PEC CEC ទី១ បញ្ហាប្រជាពលរដ្ឋមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតប៉ុន្តែមិនមានឯកសារផ្សេងទៀតដើម្បីបញ្ជាក់អត្តសញ្ញាណដើម្បីប្រើប្រាស់នៅក្នុងថ្ងៃបោះឆ្នោត ។ ក្នុងករណីនេះខាងខមហ្វ្រែលបានរកឃើញតែមិនទាន់បានកំនត់តួលេខបានច្បាស់លាស់ គ្រាន់តែបានប្រមូលព័ត៌មានបានបណ្ដើរៗហើយដូចឯកឧត្ដមអគ្គលេខាធិការបានលើកឡើងហើយថា គជប នឹងខិតខំប្រឹងប្រែងនេះគ្រាន់តែថាធ្វើម៉េចអាចបង្កើនជា ការផ្សព្វផ្សាយអប់រំបន្ថែមទៀតដល់ប្រជាពលរដ្ឋណាដែរមិនទាន់មានឯកសារបញ្ជាក់អត្តសញ្ញាណជាពិសេស អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬក៏សៀវភៅគ្រួសារឬក៏ឯកសារផ្សេងទៀតដែលគាត់អាចប្រើប្រាស់ក្នុងពេលបោះឆ្នោត ។ ដូចជាករណីនៅខាងភ្នំតូចស្រុកមង្គលបូរីខេត្ត បន្ទាយមានជ័យនោះគឺគាត់មិនទាន់មានឯកសារ ផ្សេងទៀតក្រៅពីប័ណ្ណបោះឆ្នោតទេ ហើយឥឡូវនេះប័ណ្ណបោះឆ្នោតមិនត្រូវបានអនុញ្ញាតិឱ្យប្រើទៀតអញ្ចឹងគាត់មិនមានឯកសារអ្វីត្រូវប្រើ ហើយក្រុមប្រឹក្សាជុំមួយចំនួនអត់ព្រមចេញទំរង់១០១៨ឱ្យគាត់ នេះជាការព្រួយបារម្ភមួយដែរ។

ទី២ទាក់ទងនិងដំណើរការជ្រើសរើសគណៈកម្មាធិការខេត្តក្រុងបោះឆ្នោត និងគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោត ។ ក្នុងដំណើរការជ្រើសរើសនេះខុមហ្វ្រែលបានសង្កេតមើលហើយបានទទួលព័ត៌មានពីភាពមិនប្រក្រតីមួយចំនួន តែបើប្រៀបធៀបទៅនិងដំណាក់ កាលបោះឆ្នោត ២០០២-២០០៣ភាពមិនប្រក្រតីនេះថយចុះ ប៉ុន្តែនៅតែកើតមានដដែរ ទី១ទាក់ទងទៅនិងការផ្សព្វផ្សាយពីការជ្រើសរើសមន្ត្រី ខេត្តក្រុងរៀបចំការបោះឆ្នោតមិនសូវបានទូលំទូលាយ ។ ទី២ គណៈកម្មាធិការខេត្តក្រុងបោះឆ្នោតបានជ្រើសរើសមកនេះមិនបានតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាដូចដែលបានចែងក្នុងបទបញ្ជារនិងនីតិវិធីរបស់ គជប ។ ភាគច្រើនសវតាដែលគណៈកម្មាធិការខេត្តក្រុងបោះឆ្នោតគឺច្រើនតែចេញមកពីគណបក្សកាន់អំណាច ។ បញ្ហាដូចជាការជ្រើសរើស PEC នេះគឺមានបញ្ហាសូកប៉ាន់មានការទទួលសំណូកនេះ ជាពិសេសលេចឮទាំងអស់គ្នា ហើយតាមរយៈប្រភពផ្សព្វផ្សាយព័ត៌មានក៏ដូចជាបណ្ដឹងប្រជាពលរដ្ឋមួយចំនួនដែលមិនសុខចិត្តថាពីមុនគាត់ធ្លាប់ជាសមាជិក PEC ប៉ុន្តែដល់ឥឡូវគាត់មិនបានជាប់ ដោយសារមិនមានការសូកប៉ាន់ និងទទួលសំណូកជាពិសេសគឺនៅ ខេត្តរតនគិរី ហើយមួយទៀតគឺបក្សពួកនិយមគឺនៅខេត្ត ឧត្តរមានជ័យដែលមានការយកកូនយកបងប្អូនយកមកធ្វើបានជាប់ជាសមាជិក PEC ហើយ PEC ពីមុនៗនោះមិនបានជាប់ ។ ពេលខុមហ្វ្រែលបានជួបសួរគាត់ គាត់ថាបើសិនអ្នកនោះមានសមត្ថភាព មានបទពិសោធន៍ជាងគាត់ គាត់មិនសូវជាខ្វល់ខ្វាយទេ ប៉ុន្តែនេះជាអ្នកថ្មីសុទ្ធ ហើយជាក្រុមគ្រួសាររបស់ PEC ទៀត ។ ពាក់ព័ន្ធទៅនិងការសូកប៉ាន់ក្ដី បក្សពួកក្ដី ខុមហ្វ្រែល បានឱ្យគាត់ដាក់ពាក្យប្ដឹងហើយ ប៉ុន្តែគាត់លើក ថាខ្លាចមានការប្រឈមខ្លាំងសូមតែផ្ទាល់មាត់បាន ។ ចំពោះករណីនេះ ខុមហ្វ្រែលគិតថា គជប ឬអាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់គឺជា អាជ្ញាធរមួយដែលគេតាមមើលគ្រប់គ្នា ហើយអាជ្ញាធរដែលធានាអព្យាក្រឹត្យ ធានាឯករាជ្យក្នុងការរៀបចំការបោះឆ្នោត គណបក្សនយោបាយបានផ្ដល់ទំនុកចិត្តនៅពេលដែលមានបញ្ហាអញ្ចឹងកើតឡើងគេគិតថា នៅពេលដែលជ្រើសរើសសមាជិក PEC CEC គឺយកលុយហើយ តើមន្ត្រីដែលទៅរៀបចំការបោះឆ្នោតរំពឹងបានអ្វីមកវិញ បើប្រាក់ឧបត្ថមសំរាប់ការធ្វើការងារបោះឆ្នោតនោះមិនបានច្រើនផង ក្នុងរយៈពេលតែតិចខែ ហើយគាត់ សុខចិត្តចំណាយ ឬមួយក៏ត្រូវបានគេកំណត់ឱ្យបង់ប្រាក់ខែគាត់១ខែឬក៏ប៉ុន្មាននោះ?យើងធ្លាប់បានឮហើយដូចជា PEC នៅខេត្តរតនគិរីកាលពីលើកមុនមានការកិបកេង ទ្រព្យសម្បត្តិ សំភារៈបោះឆ្នោតយកទៅលក់រហូតដល់ទឹកប្រាក់៥ពាន់ដុល្លា នេះតាមរយៈវិទ្យុសេរីលើកឡើងទេហើយផ្ដល់ផលប៉ះពាល់ដល់ដំណើរការរៀបចំការបោះឆ្នោតដែរ ។ នៅខេត្តកំពង់ចាមក៏មានដែរ ហើយថ្នាក់ CEC គឺនៅក្នុងស្រុកមេម៉ត់ ស្រុកបាធាយ ហើយនិងស្រុកពញាក្រែកដែលបានទទួលព័ត៌មានមក ហើយក្នុងនាមជាអ្នកសង្កេតការណ៍យើងមានវិជ្ជាជីវៈមួយចង់ឱ្យមានភស្តុតាង ឱ្យមានសាក្សីត្រឹមត្រូវប៉ុន្តែខិតខំទំនាក់ទំនងជាមួយអ្នកដែលគាត់ខំមកប្ដឹងនោះគឺថាគាត់មិនហ៊ានបញ្ចេញមុខក្នុងការប្ដឹងតវ៉ា ហើយឯកសារក៏មិនមាន ធម្មតាជាការសូកប៉ាន់គឺធម្មតាមិនមាន ឯកសារដូច្នេះមិនមែនថាខុមហ្វ្រែលចេះតែលើកឡើងទេគឺករណីនេះមានតែ ដោយខុមហ្វ្រែលមិនមានសមត្ថកិច្ចទៅធ្វើការស៊ើបអង្កេតប៉ុន្តែដល់ឥឡូវខុមហ្វ្រែលសុំសំនូមពរដល់ គជប ថាធ្វើម៉េចឱ្យរាល់ព័ត៌មានដែល គជប ទទួលបានសូមឱ្យ គជប មេត្តាចុះទៅចាត់វិធានការណ៍ស៊ើបអង្កេតឱ្យបានស៊ីជំរៅនៅទីកន្លែងដែលមាន ។

ទី៣ ទាក់ទងនិងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ ។ ចំនុចមួយដែលខុមប្រែ្វលធ្លាប់បានលើកជាការព្រួយបារម្ភទាក់ទងទៅ និងការបញ្ជាក់ពីអាជ្ញាធរឃុំសង្កាត់ ហើយឥឡូវនេះរឿងនេះបានកើតឡើងពិតមែន គឺទាក់ទងទៅនិងការលំបាកក្នុងការបញ្ជាក់ពីមេឃុំ ដើម្បីបញ្ជាក់ថាគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៅក្នុងឃុំសង្កាត់ហ្នឹងមានការយឺតយ៉ាវ ឬមានការរើសអើង ឬមានការទំនាក់ទំនងមិនល្អរវាង គណបក្សនយោបាយនិងក្រុមប្រឹក្សាឃុំសង្កាត់ ហើយ ខុមប្រែ្វល ក៏ធ្លាប់បានលើកជាអនុសាសន៏ដែរថា បើគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតហើយ តើយើងអាចសំរួលឱ្យគាត់ភ្ជាប់ថតចំលងប័ណ្ណព័ត៌មាន ទៅនិងឯកសារដើម្បីដាក់ពាក្យ ជាបញ្ជីបេក្ខជនបានទេ ព្រោះប័ណ្ណព័ត៌មានចេញមកពី គជប មានន័យថាជាការទទួលស្គាល់របស់ គជប មួយហើយអាចជាការជំនួសមួយដែរ ។ ហើយមួយទៀតបើបេក្ខជនខ្លួនគាត់ បើគាត់មិនបានប័ណ្ណព័ត៌មាននោះទេ ប៉ុន្តែគាត់ចាំលេខកូដ ចាំលេខរៀង លេខការិយាល័យ ឈ្មោះការិយាល័យបោះឆ្នោតច្បាស់លាស់ឱ្យគាត់សរសេរបំពេញនៅលើទំរង់បញ្ជី របស់បេក្ខជនមួយទៅ ថា ឈ្មោះគាត់នៅការិយាល័យលេខនេះ ឈ្មោះនេះគឺថាបាន ហើយគណៈកម្មាធិកាឃុំសង្កាត់រៀបចំការបោះឆ្នោតគ្រាន់តែយកឈ្មោះនេះយកទៅផ្ទៀងជាមួយនិងបញ្ជីបោះឆ្នោតដែល គជប បានផ្តល់ឱ្យគឺថាអាចជួយសំរួលទាំងពេលវេលាឱ្យគាត់ ហើយគិតថាមិនទាស់ខុសទេ ព្រោះទាល់តែគាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានគាត់អាចឈរឈ្មោះជាបេក្ខជននៅក្នុងឃុំសង្កាត់បាន។

ទី៤ ទាក់ទងនិងការការពារសន្តិសុខ ជាសំនូមពរគឺដូចជាការពាក់ព័ន្ធទៅលើករណីឃាតកម្មដែលបានកើតឡើងនៅតាមមូលដ្ឋានមួយចំនួនប៉ះទៅនិងសកម្មជនគណបក្សនយោបាយ ហើយគិតថាជាសំនូមពរសុំឱ្យខាងអាជ្ញាធរមានសមត្ថកិច្ច ធ្វើយ៉ាងណាខិតខំស្វែងរកចាប់ជនដៃដល់ឱ្យបាន ព្រោះកន្លងមកករណីឃាតកម្មភាគច្រើនដែលប៉ះទៅលើសកម្មជនគណបក្សនយោបាយនោះគឺថាមិនសូវចាប់ជនដៃដល់មកដាក់ទោសទេច្រើនតែរួចទៅបាត់ស្ងាត់ឈឹងទៅតាំងពីឆ្នាំ២០០២-២០០៣មករឿងមួយចំនួននោះអត់ឃើញមិនដឹងថាឃាតករនៅឯណា មិនដឹងថារឿងនោះជារឿងអ្វីគឺនៅតែស្រពេចស្រពិលទាំងអស់គ្នា ។ ដូចនេះសុំឱ្យអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការណ៏ឱ្យបានជាក់ស្តែង ខិតខំស្វែងរកជនដៃដល់ឱ្យបានយកមកវិនិច្ឆ័យទោសឱ្យបានដឹងច្បាស់ថា រឿងនោះរឿងអ្វីដើម្បីកុំឱ្យនៅតែមានការ ចោទប្រកាន់ពីគណបក្សដែលរងគ្រោះនោះថាជា ឃាតកម្មនយោបាយ ។

ទាក់ទងនិងក្រុមការងារដែលចែកប័ណ្ណព័ត៌មានសំរាប់ពេលខាងមុខនេះ ។ តាមការកត់សំគាល់របស់លោកគឺពីមុនចែកហើយសល់ទុកនៅទីស្នាក់ការឃុំសង្កាត់ប៉ុន្តែឥឡូវនេះមានការផ្លាស់ប្តូរ គឺយកមកទុកនៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតវិញ ហើយប្រជាពលរដ្ឋមួយចំនួនដឹងហើយថាកាលណាអត់បានមេភូមិចែកឱ្យគាត់ គាត់ទៅយកនៅសាលាឃុំប៉ុន្តែអីឥឡូវនេះនៅពេលដែលគាត់មិនបានទទួលបានប័ណ្ណព័ត៌មានគាត់ត្រូវទៅយកនៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតវិញ នេះគ្រាន់ជាការចាប់អារម្មណ៏ផ្លាស់ប្តូរដែលអាចឱ្យប្រជាពលរដ្ឋមានការយល់ច្រឡំហើយរកអត់ឃើញ ។

ក៏សុំសំនូមពរដល់ គជប បើសិនជាអាចធ្វើទៅបានគឺនៅកាលប្រជុំលើកក្រោយ គឺចង់ដឹងអំពីចំនាយសរុបនៅក្នុងដំណើរការចុះឈ្មោះអ្នកបោះឆ្នោតនេះតើ គជប បានចំនាយថវិការចំនួនប៉ុន្មាន ? ដើម្បីរៀបចំនៅក្នុងការចុះឈ្មោះអ្នកបោះឆ្នោតកន្លងមកនេះ។

**លោក ថាច់ ឈួនយ៉ាត** អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធមនុស្សខ្មែរកម្ពុជាក្រោម បានបង្ហាញពីការព្រួយបារម្ភចំពោះខ្មែរកម្ពុជាក្រោមមានចំនួនច្រើនិ នបានអត្តសញ្ញាណប័ណ្ណ ហើយម្យ៉ាងទៀតមួយចំនួនដែលគាត់បានធ្វើអត្តសញ្ញាណប័ណ្ណហើយតាំងពីឆ្នាំ២០០២ ជាពិសេសនៅឃុំឃ្លួនខណ្ឌឬស្សីកែវ រហូតមកដល់ពេលនេះមិនបានទទួលអត្តសញ្ញាណប័ណ្ណទេ ។ ពួកគាត់ភាគច្រើនបានបោះឆ្នោតតាំងពីឆ្នាំ ២០០២-២០០៣ ហើយប៉ុន្តែបោះឆ្នោត ឆ្នាំ២០០៧ នេះមិនបានផ្តល់ប័ណ្ណបោះឆ្នោតដូចពីមុនទៀតទេ នឹងយកអត្តសញ្ញាណប័ណ្ណពិនិត្យទៅតាមឈ្មោះដែលមាននៅក្នុងបញ្ជីបោះឆ្នោតរបស់ គណៈកម្មាធិការរៀបចំការបោះឆ្នោត ។

**លោក ឱក សេរី សោភក្តិ៍** សូមធ្វើការបំភ្លឺចំពោះតំណាងខ្មែរកម្ពុជាក្រោមមួយទៀតដែលធ្លាប់មកធ្វើការចូលរួមប្រជុំពីមុនថាសមាជិកខប់សែលមានលោកវិរៈសេនីយ៏ពីររូបដែលជាសមាជិកខប់សែល ហើយដែលលោកទទួលរឿងអត្តសញ្ញាណប័ណ្ណតែម្តង ដូច្នេះនេះជាឱកាសមួយដ៏ពិសិទ្ធ បើសិនអាចមានបញ្ជីឈ្មោះអ្នកណាដែលមិនទាន់បាននោះ លោកអាចជួបជាមួយគាត់ទាំងពីរនាក់ផ្ទាល់ដើម្បីដោះស្រាយ ។

**លោក ឪណា សាគុណ** មកពីគណបក្ស សម រង្ស៊ី បានសួរថាបញ្ហាគណបក្ស សម រង្ស៊ី មានការព្រួយបារម្ភទាក់ទងនិងបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំសង្កាត់សំរាប់ការបោះឆ្នោតនៅថ្ងៃទី០១ខែមេសាឆ្នាំ២០០៧នេះ ។ ទាក់ទងនិងបញ្ជីបេក្ខជនគណបក្ស សម រង្ស៊ីមានការព្រួយបារម្ភថា សុពលភាពរបស់បញ្ជី បោះឆ្នោតគឺនៅថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៦ ហើយការដាក់ពាក្យបេក្ខជនឃុំនៅថ្ងៃទី០១ ដល់ថ្ងៃទី ០៣ខែមករាឆ្នាំ ២០០៧ ដូច្នេះកំឡុងពេលមានការតិចតួចពេកក្នុងការដាក់ពាក្យ ទាក់ទងនិងការងារនេះបេក្ខជនគណបក្ស សម រង្ស៊ី ខ្លះបានការបញ្ជាក់ហើយ ឃុំខ្លះក៏មិនទាន់បញ្ជាក់ឱ្យដោយសារ បញ្ជីសុពលភាពនេះមិនទាន់ចេញជាផ្លូវការ អញ្ចឹងការបញ្ជាក់គណបក្ស សម រង្ស៊ីបារម្ភថាការបញ្ជាក់ហ្នឹងមិនទាន់ពេលវេលា ។ គណបក្សទាំងអស់ដែលមាន ការខ្វះនីតិវិធី ធម្មតានីតិវិធីនេះមានហើយនៅក្នុងច្បាប់ខាងលើ ប៉ុន្តែនៅខាងក្រោមគ្មានសៀវភៅ គ្មាននីតិវិធីឱ្យគាត់មើលទេដូចនេះការដាក់នេះមាន ម្តងខុសពីរដងខុសបីដងខុសនៅតែមានខុស ។ យើងតែងតែជជែកគ្នាថា មិនមើលនីតិវិធី មើលសៀវភៅចេញប៉ុន្តែសៀវភៅមាននៅតែខាងលើទេ មិនមែនចែកទៅដល់ថ្នាក់ឃុំឬក៏មន្ត្រីនយោបាយ ឬក៏អ្នកនៅមូលដ្ឋានឱ្យបានច្រើន ជិតដល់រឿងឯកសារទេ ។ គណបក្ស សម រង្ស៊ី សំនូមពរឱ្យបញ្ហា នីតិវិធីក្នុងការដាក់ពាក្យបេក្ខជនឱ្យបានជ្រួតជ្រាប ជាពិសេសសៀវភៅដែលមាននីតិវិធីដែល គជប ចែងឱ្យបានយល់ទៅដល់ក្រុមប្រឹក្សាឃុំសង្កាត់ ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ទាក់ទងទៅនិងនីតិវិធីនៃការដាក់ពាក្យដែរសូម គជប ផ្តល់ជាគំរូមួយសំរាប់ឱ្យឃុំសង្កាត់ទាំងអស់យក ជាគំរូតាមឧទាហរណ៍ លើកជាឃុំណាមួយដែលត្រូវបំពេញបែបបទនៅក្នុង គជប ទីមួយបញ្ជីដាក់ពាក្យបេក្ខជនណាទំរង់ណាដែលត្រូវមានបិទរូបថត បញ្ជីបេក្ខជន ៦ ច្បាប់ ដើម្បីឱ្យនៅមូលដ្ឋានគាត់មិនច្បាស់និងការដាក់ពាក្យធ្វើតាម ។

ទាក់ទងនិងភ្នាក់ងារនេះដែរ លោកសំនូមពរឱ្យជួយសំរួលនីតិវិធីថា បេក្ខជនដាក់ឈរឈ្មោះឃុំមួយក៏អាចធ្វើជាភ្នាក់ងារបាននៅឃុំនេះដែរ ។ ព្រោះបេក្ខជននេះខិតខំណាស់ដោយសារលទ្ធផលរបស់គេគឺបានខ្លួនគេមិនអាចក្បត់ខ្លួនគេ លក់ឧត្តមគតិ ឬក៏អាចទិញទឹកចិត្តបានទេ ។ នេះជាចំនុចល្អមួយដែរយើងគួរតែទទួលស្គាល់ទាំងអស់គ្នា តែបានមកលើខ្លួនឯងហើយគឺខំយកចិត្តទុកដាក់ណាស់ដើម្បីធ្វើ ឱ្យមានតម្លាភាពជាទីបំផុតបើមិនដូចនេះទេបណ្តាលឱ្យមានការទិញដូរ សូកលុយ ការគំរាមកំហែងជាដើម ។ លោកសុំបញ្ជាក់ថាតើភ្នាក់ងារ ត្រូវមានរូបថតរូបថតប៉ុន្មាន?

ទាក់ទងនិងខាងប៉ូលិសលោកសូមអរគុណចំពោះក្រសួងមហាផ្ទៃ ដែលបានផ្តល់អត្តសញ្ញាណប័ណ្ណទៅដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ប៉ុន្តែសព្វថ្ងៃនេះប្រជាពលរដ្ឋមានជីវភាពក្រីក្រ ហើយអំពើរពុករលួយកើតមាននៅទូទាំងប្រទេស អញ្ចឹងការផ្តល់ អត្តសញ្ញាណប័ណ្ណនេះ មានការកិបកេងតិចតួចទៅលើការផ្តល់អត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋ ។ ដូចនេះសំនូមពរថាខាងក្រសួងមហាផ្ទៃគួរតែជំ រុញបន្ថែមដល់មន្ត្រីនៅក្រោមឳវាទរបស់ខ្លួនឱ្យសកម្មចំនាយពេលវេលាដ៏មានតំលៃជួយប្រជាពលរដ្ឋខ្មែរផ្តល់អត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋខ្មែរដោយយកចិត្តទុកដាក់ នេះចំពោះប្រជាពលរដ្ឋខ្មែរ ។ គណបក្ស សម រង្ស៊ី មានការសោកស្តាយខ្លាំងណាស់នៅពេលដែល អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរផ្តល់ទៅឱ្យជនអន្តោប្រវេសន្តបរទេសជាពិសេសជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជាដែរពុំស្របច្បាប់ ។ នៅក្នុងពិភពលោកនេះ គ្រប់ប្រទេសស្រលាញ់ជាតិសាសន៍គេណាស់គេមុននឹងឱ្យអត្តសញ្ញាណប័ណ្ណជាតិរបស់គេទៅជនណាមួយ គេពិនិត្យច្បាស់លាស់ខ្លាំងណាស់ ។ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានតំលៃសំរាប់ជាតិសាសន៍គេសំរាប់ខ្មែរ ជនបរទេសនិយាយភាសាខ្មែរមិនច្បាស់ផង កាន់អត្តសញ្ញាណប័ណ្ណខ្មែរ គួរឱ្យខ្មាសគេដែរ ។ លោកសំនូមពរមួយទៀតទាក់ទងនិងរឿងអត្តសញ្ញាណប័ណ្ណនេះ សុំឱ្យធ្វើជំរឿនចុង ក្រោយមើលថា តើជនដែលមិនចេះភាសាខ្មែរ មិនយល់ពីវប្បធម៌ខ្មែរ ឬអ្វីផ្សេងទៀតរបស់ខ្មែរនោះ តើក្រសួងមហាផ្ទៃមានវិធានការណ៍នឹងបោសសំអាតទេ ហើយទៅថ្ងៃមុខនៅតែដូចនេះទៀតគណបក្ស សម រង្ស៊ីមានការព្រួយបារម្ភជាទីបំផុត ។ ទាក់ទងរឿងសន្តិសុខដែររឿងអាយកូមទៅដល់ មន្ត្រីប៉ូលិសជារៀងរាល់លើកនៅក្នុងការិយាល័យបោះឆ្នោតអស់លោកដែលមានតួនាទីជាប៉ូលិសនោះគាត់បើកសំលេងអាយកូមឮខ្លាំងពេករំខានប៉ះ ពាល់ទៅដល់អ្នកបោះឆ្នោត ភាសាខ្លះនៅក្នុងអាយកូមដែរបានថតបានខ្លះនោះថាមើលឯងមើលអានោះមើលមកហើយ មើលអានោះវាមួយទៅ នេះជាភាសាបច្ចេកទេសរបស់ប៉ូលិស ប៉ុន្តែអ្នកដែលទៅបោះឆ្នោតមានការព្រួយបារម្ភ ។ ដូចនេះសុំឱ្យសំលេងអាយកូមរបស់មន្ត្រីប៉ូលិសដែលមានតួនាទីនៅក្នុងការិយាល័យនិមួយៗសុំឱ្យបន្ថយសំលេងប្រើសំរាប់ស្តាប់តែម្នាក់ឯងបានហើយកុំឱ្យរំខានដល់អ្នកបោះឆ្នោត ។

ទាក់ទងនិងការសំលាប់មន្ត្រីគណបក្សនយោបាយរាល់លើកមន្ត្រីខាងជំនាញតែងតែយកលេសថាជារឿងនយោបាយ ។ ក្នុងនាមជាប៉ូលិសត្រូវស៊ើបអង្កេតថា តើការសំលាប់នេះមកពីមូលហេតុអ្វី? រកឱ្យឃើញមុនសិនចាំធ្វើអត្ថាធិប្បាយជាក្រោយ ធម្មតាគណបក្ស សម រង្ស៊ី តែងតែ ថាដូចនេះ ព្រោះអ្នកដែលសំលាប់គឺជាមន្ត្រីគណបក្ស សម រង្ស៊ី ពិតប្រាកដមែន អញ្ចឹងគណបក្ស សម រង្ស៊ី ថារឿងនេះជារឿងនយោបាយ ហើយប៉ូលិសក៏ថារឿងនេះជារឿងនយោបាយ ប៉ុន្តែប៉ូលិសត្រូវធ្វើការស៊ើបអង្កេតថា ត្រូវចាប់ជនដៃដល់ឱ្យបានមុន និងធ្វើការអំណះអំណាងទៅដល់ កាសែតជាតិ ឬអន្តរជាតិកន្លងមកមិនទាន់ចាប់ជនដៃដល់បានផងធ្វើការអះអាងមុន ។ ចំពោះការប្រើប្រាស់អាវុធរបស់ក្រុមមន្ត្រីប៉ូលិសវិញ គណបក្ស សម រង្ស៊ី ញញឹត ណាស់ជូនកាលស្លៀកពាក់ស៊ីវិលសកកាំភ្លើង ធ្វើឱ្យមានការខ្លាចពីមជ្ឈដ្ឋានសាធារណៈ ។

**ឯកឧត្តម ទេព នីថា** ធ្វើការបកស្រាយចំពោះបញ្ហាដែរឯកឧត្តម អ៊ុក ភូរី មានប្រសាសន៍ គជប នឹងធ្វើអន្តោគមន៍បន្ថែមទៀតទៅខេត្តព្រះវិហារ ព្រោះ គជប បានទទួលទូរសព្ទ័ពីឯកឧត្តមប្រហែលជាប្រាំថ្ងៃមុននេះ គជប បានឱ្យទៅថ្នាក់ខេត្តគេដោះស្រាយហើយ ហើយឥឡូវនេះទើបនិងបានពីរស្រុកនៅសល់មួយស្រុកទៀត ។ គជប និងរំលឹកបញ្ហានេះឡើងវិញ តើជាប់បញ្ហាដោយសាររឿងអ្វី ? ព្រោះបើពិនិត្យមើលទៅលើច្បាប់ស្តីពីគណបក្សនយោបាយនៅថ្នាក់ខេត្តមិនមែនមានសិទ្ធសំរេចទទួលស្គាល់ ឬមិនទទួលស្គាល់គណបក្សនោះទេ គឺមានតែលិខិតទៅពីលើទៅគណបក្សអាចធ្វើសកម្មភាពបានទៅតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ហានេះ ឯកឧត្តមគិតថាទី១ បើតាមការធ្វើសកម្មភាពផ្សេងៗ នោះអាចទាក់ទងនិងអាជ្ញាធរ ប៉ុន្តែបើការបញ្ជាក់ឈ្មោះបេក្ខជននៅលើបញ្ជីបោះឆ្នោតទាក់ទងទៅនិងមេឃុំ ចៅសង្កាត់ ហើយទាក់ទងទៅនិង គណៈកម្មាធិការខេត្តក៏ដូចជា គជប ហើយបញ្ហានេះ គជប នឹងរំលឹកឡើងវិញ ហើយដោយឡែក នៅខេត្តកណ្តាល ការឱ្យទៅបង្ហាញខ្លួន ខ្លះនោះជានិតិវិធីរដ្ឋបាលរបស់ឃុំសង្កាត់ដែរ ព្រោះមានគណបក្សខ្លះ នោះយកឈ្មោះគេ ជាបេក្ខជនមក ហើយមានលិខិត ស្នាមមែន ក៏ប៉ុន្តែនៅពេលគេសួរម្នាក់ គាត់ថាគេអត់មានឈរឈ្មោះឱ្យគណបក្សនេះទេ នៅខេត្តកណ្តាលមានបញ្ហានេះ ទើបបាន ជាមេឃុំតំរូវឱ្យ បេក្ខជនមកបង្ហាញខ្លួន ។ ហើយបញ្ហានេះក៏ធ្លាប់កើតនៅក្នុងឆ្នាំ២០០២ ដែរ ហើយ គជបសន្យាថានឹងដោះស្រាយបញ្ហានេះដើម្បីឱ្យថ្នាក់ខេត្តជួបជាមួយមេឃុំ ចៅសង្កាត់បញ្ជាក់បញ្ហានេះច្បាស់ ។ ព្រោះដូចការចុះឈ្មោះបោះឆ្នោត ត្រូវមានសាក្សី២នាក់បញ្ជាក់ទំរង់ ១០១៨ ឬ១០១៩ ហើយមេឃុំមុននឹងបញ្ជាក់ឱ្យពី១០១៩ដាច់ខាត ត្រូវមេភូមិធ្វើចំណារឱ្យគាត់មួយបានគាត់បញ្ចេញឱ្យ ។ ច្បាប់ថាមិនមានឱ្យមេភូមិធ្វើទេ ហេតុអ្វីបានឱ្យមេភូមិធ្វើ តាមពិតច្បាប់អត់មាននិយាយមែន ប៉ុន្តែមេឃុំគាត់ធ្វើការជាមួយមេភូមិរបស់គាត់ជានីតិវិធីរដ្ឋបាលរបស់គាត់ ព្រោះមេភូមិនេះនៅជាមួយប្រជាពលរដ្ឋ បើមេភូមិមិនស្គាល់ផងហើយសេចក្តីណែនាំរបស់ក្រសួង មហាផ្ទៃក៏ដូចជា គជប ដែរថាអ្នកដែលធ្វើសាក្សីបានទាល់តែអ្នកនោះផ្ទះជិត ហើយអ្នក ដែលជាមុខជាមាត់របស់មេឃុំនោះគឺមេភូមិ ។

ទី២ទាក់ទងទៅនិងខុមប្រ្យែល បញ្ហាប្រជាពលរដ្ឋអត់ឯកសារទៅបោះឆ្នោត។ គជប បានផ្សព្វផ្សាយហើយ ។ ហើយលោកតំណាងខ្មែរកម្ពុជាក្រោមក៏បានលើកពីបញ្ហានេះដែរ ហើយ គជប នឹងជូនដំណឹងបន្ថែមទៀតព្រោះថា ការប្រើប្រាស់ឯកសារ ដើម្បីបោះឆ្នោត នោះ អាចមានឯកសារច្រើនហើយដែលចង់បានគឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហើយបើអត់មានអីទាំងអស់ទើបប្រើទំរង់ ១០១៨ ។ ចំពោះការជ្រើសរើសបុគ្គលិកវិញ គជប ក៏ដូចជាខុមប្រ្យែលដែរ គ្មានលិខិតប្តឹងជាផ្លូវការទេ ទទួលព័ត៌មានដូចគ្នាហើយគ្មាន នរណាម្នាក់ចេញមុខធ្វើសាក្សីលើបញ្ហានេះទេ ហើយរាល់ការជ្រើសរើសតែងតែមានបញ្ហានេះ ហើយជាការពិបាកសំរាប់ គជប នៅពេលដែល ជ្រើសរើសអ្នកដែលធ្លាប់ ធ្វើការបោះឆ្នោតទាំងអស់អ្នកថ្មីគេតវ៉ាថា រើសតែគ្នាឯងអ្នកធ្វើការបោះឆ្នោត ។ ដល់ឆ្នាំនេះឱ្យខេត្តធ្វើការជ្រើស រើសឱ្យមានអ្នកថ្មី៣០ភាគរយនៅក្នុងហ្នឹង អ្នកចាស់ប្តឹងមកតវ៉ាមកថា រើសតែអ្នកថ្មីអត់ពិសោធន៍សោះ ហើយអ្នកចាស់ធ្លាក់ ។ របៀបធ្វើការរបស់ គជប គឺម៉ត់ចត់ណាស់ អ្នកធ្វើការបោះឆ្នោតហើយនិមួយៗតែងតែមានក្រដាសវាយតំលៃមួយទាំងអ្នកធ្វើការនៅ ការិយាល័យបោះឆ្នោត តែប្រាំថ្ងៃ តែបីថ្ងៃក៏មានក្រដាស វាយតំលៃមួយដែរថាអ្នកនេះធ្វើការត្រឹមត្រូវទេ យុត្តិធម៌ទេ មិនលំអៀងទេ គឺឧបមាថា ប្រាំ នាក់ឱ្យ៤នាក់វាយតំលៃលើម្នាក់ហើយហត្ថលេខាលើឯកសារហ្នឹងទុកនៅ គជប ទាំងអស់ ដូចនេះនៅពេលជ្រើសរើស គជប ចាប់ផ្តើមពិនិត្យ មើលឈ្មោះនោះឡើងវិញនិងសំរេច ហើយការងារនេះ គជប ផ្អែកលើឯកសារចាស់ បើអ្នកខ្លះធ្លាប់ធ្វើការបោះឆ្នោតដែរ តែនៅពេលធ្វើការបោះឆ្នោត នោះបំពេញការងារមិនបានល្អ មានបញ្ហា គជប ពិនិត្យមើលបញ្ហានេះ អត់យកទេ

ក៏ប៉ុន្តែអ្នកខ្លះទៀតក្នុងករណីធ្លាប់ធ្វើការបោះឆ្នោតដែរ តែលក្ខខ័ណ្ឌអ្នកដែលត្រូវជ្រើសរើសយក៣នាក់មកសំភាសន៍នោះថា តើអ្នកណាមួយគេល្អជាងគេយកអ្នកនោះ។ ហើយការដែលមានបញ្ហាផ្សេងៗ ជៀសមិនផុតទេ ហើយ គជប បានទទួលលិខិត២ពីខេត្តកំពង់ចាម និងពីខេត្តកណ្តាល ចំពោះនៅខេត្តកំពង់ចាម គឺមានអ្នកចង់ធ្វើការនៅថ្នាក់ខេត្ត ម្នាក់ត្រូវឱ្យលុយគេពី ៥០០ ទៅ ១០០០ ដុល្លា តើអ្នកនេះមកធ្វើការ ឬមកស៊ីកគេ ព្រោះធ្វើការប៉ុន្មានខែហ្នឹង បើថ្នាក់សមាជិក PEC នោះគឺអាច នៅសល់លុយតិចបំផុត តែបើនៅថ្នាក់ក្រោមគ្រាន់តែយក លុយទៅស៊ូកគេនោះមិនគ្រប់ផង ដូចនេះមិនត្រឹមត្រូវសោះបញ្ហានេះ ។ បញ្ហា នៅឃុំកំពង់ចាមមួយចំនួនដែលបានលើកនេះ គឺ គជប បានដឹងព័ត៌មានមុនការជ្រើសរើសទៀត ហើយគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោតនោះ ចុះទៅកន្លែងនោះផ្ទាល់ដើម្បីចាត់វិធានការណ៍នៅមុនការជ្រើសរើស ព្រោះព័ត៌មាននេះមិនទាន់ចុះជ្រើសរើសផង គ្រាន់តែចែក និងព្ទថាយកលុយទៅ ហើយ មានឈ្មោះរួចអស់ហើយ ។ មានការសំភាសន៍ជាមួយវិទ្យុមួយចំនួនគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត បានចាត់វិធានការណ៍ មុនមួយ ចំនួនហើយ បើមានភស្តុងតាងច្បាស់លាស់ គជប និងចាត់វិធានការណ៍ភ្លាម ឧទាហរណ៍ ដូចនៅខាងរតនគីរីដែលខាងខុមហ្វ្រែលនិយាយថា បានលក់អីវ៉ាន់បោះឆ្នោតបាន៥០០០ដុល្លា ។ ខេត្ត នោះមានសំភារៈមានតំលៃមិនបានដល់៥០០០ដុល្លាទេ ។ ការជ្រើសរើសនៅរតនៈគីរីមានការលំបាករកមនុស្សមានសមត្ថភាព នៅក្នុងការបំពេញការងារទៀត ការដែលស៊ូកចង់ទៅធ្វើការ នៅរតនគីរីនោះមានតិចណាស់ ព្រោះថាឥឡូវនេះមានបញ្ហាក្នុងការជ្រើសរើស ដោយខ្វះមនុស្សទៀត ព្រោះថាក្រសួងអប់រំមិនចង់ឱ្យគ្រូដែលទទួលបន្ទុកនៅក្នុងថ្នាក់និមួយៗ ទៅធ្វើការងារបោះឆ្នោតទេ ហើយមន្ត្រីរៀបចំការបោះឆ្នោតពី មុនៗមកភាគច្រើនគឺជាគ្រូបង្រៀន ហើយដល់គ្រូដាក់ក៏រិត ខ្វះអ្នកទៅដាក់ពាក្យ បើគ្រូធ្វើការនៅការិយាល័យគេអនុញ្ញាតិឱ្យយក តែបើគ្រូនោះទទួលថ្នាក់ហើយ នៅពេលគ្រូនោះមកធ្វើការ បោះឆ្នោតខេត្តអាច ៩ខែ ឬថ្នាក់ឃុំ៤ខែ គឺត្រូវបោះបង់ចោលសិស្សរបស់គាត់នោះ ធ្វើឱ្យមានបញ្ហា សូម្បីតែខេត្តកណ្តាល កន្លែងខ្លះដាក់ពាក្យ យកមកសំភាសន៍មិនបាន ៣នាក់ទេក្នុងមួយប៉ុស្តិ៍ ។ បញ្ហាមួយទៀតនៅខេត្តកណ្តាល គជប បានឱ្យមន្ត្រីចុះកាលពីម្សិលមិញ ហើយដែលថាមន្ត្រីដែលចុះទៅជ្រើសរើស នោះមាន យកលុយគេ ហើយតាមព័ត៌មានអ្នកដែល ដាក់ពាក្យនោះ មិនគ្រប់ផង ព្រោះនៅក្នុងឃុំសង្កាត់ភាគច្រើនជាគ្រូ ហើយមួយចំនួនគេមកធ្វើការ នៅភ្នំពេញហើយដោយធ្វើការនៅឃុំសង្កាត់ ប្រាក់ខែត្រឹម ៩០ ដុល្លា ហើយគ្រូធ្វើនៅទីនោះគាត់សល់ប្រាក់ខែគ្រូផង គាត់មកធ្វើការ នៅទីនេះទៀត ធ្វើបាន ដល់ពេលក្រសួងមិនអនុញ្ញាតិមិនមានបេក្ខជន ហើយបើអត់មានបេក្ខជន ការស៊ូកប៉ាន់នោះក៏មិនអាចលេចរូបភាពច្រើនដែរ ។

ចំពោះការចុះបញ្ជីបេក្ខជនយកប័ណ្ណព័ត៌មាន គជប ក៏នឹកឃើញបញ្ហានេះដែរ ប៉ុន្តែច្បាប់ទាមទារលិខិតបញ្ជាក់ពីមេឃុំ ចៅ សង្កាត់ បើផ្អែកទៅលើច្បាប់ ហើយការងារនេះលំបាក ។ ក្នុងករណីដែលបេក្ខជនដាក់ទៅ ហើយគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោត បដិសេធគាត់អាចប្តឹងមកខេត្ត ប្តឹងមក គជប ហើយពេលវេលាគ្រាន់តែយឺតយូរបន្តិច ហើយការសំរេចនៅលើមូលដ្ឋានច្បាប់អាចធ្វើបាន ប៉ុន្តែជាមូលដ្ឋានចង់ឱ្យមានការបញ្ជាក់ចេញពីមេឃុំចៅសង្កាត់ព្រោះច្បាប់តំរូវ ។

ចំពោះបញ្ហាដែរថាយកប័ណ្ណព័ត៌មានទៅរក្សានៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតនេះជាការកំណត់ក្នុងសេចក្តីណែនាំថ្មី រវាង គជប និងក្រសួងមហាផ្ទៃហើយការដែលយកទៅដាក់នៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតនេះដោយម្យ៉ាងថា ពេលដែលបោះឆ្នោត នេះមេឃុំ ចៅសង្កាត់ និងក្រុមប្រឹក្សាឃុំភាគច្រើនគាត់ជាបេក្ខជន មានគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោត ហើយយកទៅដាក់នៅ គណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតតែម្តងមិនជាបញ្ហាទេ ព្រោះនៅក្នុងឃុំតែមួយទេ បើគាត់ទៅច្រឡំទៅឃុំសង្កាត់គេអាចប្រាប់គាត់ គាត់អាចមកយកនៅគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតបាន ។

ចំពោះការចំណាយសំរាប់ការចុះឈ្មោះបោះឆ្នោតនេះ គជប ពុំទាន់បានបូកសរុបទេ ព្រោះរហូតមកដល់ពេលនេះថវិការ មួយចំនួនមិនទាន់បានទូទាត់ឱ្យក្រុមហ៊ុននៅឡើយ គជប នៅជំពាក់ថវិការក្រុមហ៊ុននោះគិតមកដល់ពេលនេះប្រហែលជាង២លានដុល្លា ។ បញ្ហាថវិការ រដ្ឋាភិបាលធានា ៥០ ភាគរយគឺប្រហែល៦លានកន្លះ ហើយនៅសល់៦លានកន្លះទៀត ខាងជប៉ុនបានផ្តល់ឱ្យ ២៩០០០០០ ហើយថ្មីៗនេះទៀតទើបនិងទទួលបាន

ពីខាងកាណាដាប្រហែល៤០ម៉ឺនដុល្លាជាងទៀត ។ គជប កំពុងតែ អំពាវនាវរកថែមទៀត ហើយការចំណាយមួយចំនួននោះ ដោយសារខ្វះដែលត្រូវចំណាយនោះពុំមានប្រទេសផ្តល់ជំនួយណាដាក់មកឱ្យ ។ ការចំណាយថវិការបស់រដ្ឋាភិបាល ចាយតែលេខនៅឡើយទេ លុយមែនទែនមិនទាន់បានដកមកប្រើប្រាស់ទូទាត់ឱ្យនៅឡើយទេ ដូច្នេះនៅពេលទូទាត់ឱ្យអស់ហើយ គជប ធ្វើការបុកសរុបមួយដំណាក់កាល ។ ហើយ ចំពោះឯកសារដែលខាងខុមហ្វែលសុំនេះ គឺ គជប ជូន ព្រោះមានគំរោងជូន NGOs ប៉ុន្តែការជូនទៅតាមក៏រិតណាមួយដែលមានផែនការណ៍ ព្រោះថវិការមានក៏រិតការបោះពុម្ពមានក៏រិត ។

ចំពោះបញ្ហាដែលគណបក្ស សម រង្ស៊ីលើកឡើងទី១ ការចុះបញ្ជីបេក្ខជននេះ បញ្ហាផ្តល់សុពលភាពថ្ងៃទី៣១ខែធ្នូ នៅប្រជុំពីថ្ងៃមុនឯកឧត្តមបានជំរាបអស់ ហើយបានចាត់វិធានការណ៍មុនមួយជំហាន ទោះបីផ្តល់សុពលភាពថ្ងៃ៣១ខែធ្នូមែន ក៏ប៉ុន្តែឃុំសង្កាត់ណាដែលមិនមានបញ្ហាប្តឹង គជប អនុញ្ញាតិឱ្យចេញលិខិតបញ្ជាក់លើបញ្ជីបោះឆ្នោតតាំងពីដើមទីមកហើយ ហើយនៅពេលចុះបញ្ជីពីថ្ងៃទី០១ដល់ថ្ងៃទី០៣ ខែមករានេះទៀត ក្នុងករណីគណបក្សធ្វើបញ្ជីនេះមិនទាន់ គជប អនុញ្ញាតិឱ្យខ្ចះសេចក្តីបញ្ជាក់លើបញ្ជីបោះឆ្នោតនោះ ៥ ថ្ងៃថែមទៀត ។ ចំពោះនីតិវិធីនៃការបំពេញគំរូទំរង់ចុះបញ្ជីបេក្ខជន គជប ផ្តល់ជូនយូរហើយ ហើយគណបក្សនយោបាយរហូតមកដល់ពេលនេះដូច ពុំមានអ្នកណាសួរ គជប ថាបំពេញប្រៀបម៉េចអី ? នោះគឺមកពីគណបក្សនោះធ្លាប់បានបំពេញឯកសារនេះអស់ហើយ មិនមានលំបាកទេ ។ អ្វីដែលត្រូវបំពេញនោះគឺគណបក្សនយោបាយដែលត្រូវបណ្តុះបណ្តាលមន្ត្រីខ្លួនឯងនៅមូលដ្ឋានដើម្បីបំពេញឯកសារទាំងអស់នេះព្រោះ គជប មិនអាច បង្រៀនទៅ ដល់មូលដ្ឋាន ទាំងអស់របស់គណបក្សនយោបាយ ឬក៏ NGO ។ គជប បានផ្តល់នីតិវិធីទៅតាមដំណាក់កាលនិមួយៗ និងអ្នកទទួលខុសត្រូវ ឧទាហរណ៍ពេលចុះឈ្មោះបោះឆ្នោតចំពោះក្រុមប្រឹក្សាឃុំសង្កាត់ គជប មិនអាចប្រគល់នីតិវិធី៥០០ទំព័រជាងទៅឱ្យគាត់រៀនទាំងអស់ទេ ព្រោះការងារគាត់សំខាន់ តែពេលចុះឈ្មោះបោះឆ្នោត ដូចនេះគាត់ត្រូវចេះពេលចុះឈ្មោះបោះឆ្នោតឱ្យច្បាស់ គជប ណែនាំគាត់តែសៀវភៅដែលទាក់ទងនិងការចុះឈ្មោះបោះឆ្នោតប៉ុណ្ណោះ ហើយភារៈកិច្ចផ្សេងទៀត ឧទាហរណ៍ ទាក់ទងទៅនឹងការបញ្ជាក់ឈ្មោះលើបញ្ជីបោះឆ្នោត ធ្វើសេចក្តីណែនាំរំលឹកទៅគាត់ ។ ដូចនេះការផ្តល់នីតិវិធីទៅដល់ថ្នាក់ណាមួយនោះគឺមានក៏រិត និង មានភាពច្បាស់លាស់ល្អព្រោះតែផ្តល់ឱ្យច្រើនពេកមិនមានប្រយោជន៍ ហើយនៅចំពោះ មុខនេះគណៈកម្មាធិការឃុំសង្កាត់ រៀបចំការបោះឆ្នោតដែលជ្រើសរើសមកនោះ ក៏បណ្តុះបណ្តាលនិងផ្តល់ឯកសារឱ្យគាត់មានក៏រិតដែរ ពីការចុះឈ្មោះបោះឆ្នោតមិនមាន ប្រគល់ឱ្យគាត់ទេ គជប ប្រគល់ត្រឹមតែការចុះបញ្ជីបេក្ខជន ការឃោសនា និងការបោះឆ្នោតតែម្តង ។

ចំពោះរូបថតរបស់ភ្នាក់ងារគណបក្សនយោបាយ គឺខាងតំណាងគណបក្សនយោបាយនៅពេលបំពេញទំរង់នេះត្រូវបិទរូបថតនៅលើកាតមួយដែលត្រូវពាក់នៅលើខ្លួនដាក់មកគណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតគាត់និងបោះត្រានៅលើរូបថតនោះ នឹងអាចយកទៅពាក់ប្រើប្រាស់ ។

**លោកវីរៈសេនីយ៍ឯក ផេង ស៊ុនហេង** បញ្ហាអត្តសញ្ញាណប័ណ្ណ ដែលបានលើកឡើងថាប្រជាពលរដ្ឋក្រ ហើយមានការយកលុយពីមន្ត្រីប៉ូលិសនោះ លោកបានចុះទៅផ្ទាល់ក៏ទទួលស្គាល់ថាប្រជាពលរដ្ឋក្រដែរ ហើយប៉ូលិសក៏មានឧត្តមគតិខ្លះដែរមិនមែនចេះតែទៅទារលុយពីប្រជាពលរដ្ឋទេ ហើយត្រូវទទួលស្គាល់ថាការលំបាករបស់ប៉ូលិសយ៉ាប់ប៉ុនណា លីម៉ាស៊ីនកាត់ភក់ កាត់ទឹកទៅតាមភូមិឃុំដាច់ស្រយាល ដូច្នេះបើអស់លោកបានទៅឃើញក៏គួរអាណិតអាសូរដែរមិនមែនឃើញតែខ្មៅងងឹតទាំងអស់ទេ ។ បញ្ហាដែលលោកលើកឡើងកន្លងមកនេះ មានបញ្ហាខ្លះពីការយកលុយ គឺផ្តើមចេញពីប្រជាពលរដ្ឋ អ្នកខ្លះគាត់ដាក់ពាក្យសុំដល់ជិតបានហើយនោះគាត់ចង់បាន រហ័សដើម្បីយកទៅប្រើប្រាស់ គាត់យកលុយទៅឱ្យប៉ូលិសដើម្បីជួយធ្វើឱ្យរហ័សឱ្យគាត់ បញ្ហានេះមិនបានដូចបំណងដែលបានធ្វើឱ្យ ធ្វើឱ្យមានថាប៉ូលិសយកលុយយកកាក់ ។ ហើយលោក បានណែនាំគ្រប់មន្ត្រីប៉ូលិសខាងក្រោមទាំងអស់ដាច់ខាតមិនឱ្យយកលុយ ពីប្រជាពលរដ្ឋទេ នេះជាគោលការណ៍របស់រាជរដ្ឋាភិបាល ដែលផ្តល់ជូនដោយអត់គិតថ្លៃ ហើយសុំជំរាបថា ១សន្លឹកអត្តសញ្ញាណប័ណ្ណប៉ូលិសបាន តែ១៥០រៀលទេ។ ហើយបើមួយថ្ងៃធ្វើបាន ត្រឹម២០០នាក់ បាន៣ម៉ឺន ហើយ៣ម៉ឺនត្រូវធ្វើ៤នាក់ ហើយនៅក្នុងនោះក៏មានការសហការណ៍ពីស្រុក ទៅជួយផ្តល់បាយ ទឹកខ្លះ ។

ចំពោះបញ្ហាជនបរទេស គឺកន្លងមកការផ្តល់អត្តសញ្ញាណប័ណ្ណនេះគឺយោងទៅតាមសៀវភៅគ្រួសារ ហើយសៀវភៅគ្រួសារនេះគឺបានបញ្ជាក់អំពីសញ្ជាតិ សៀវភៅគ្រួសារនេះគឺមានគណៈវាយតំលៃអំពីសញ្ជាតិ ហើយបើផ្តល់ទៅតាមការណែនាំតាមច្បាប់ គឺមិនអាចផ្តល់ឱ្យជនបរទេសទេ ។ ក៏ប៉ុន្តែអ្នកខ្លះក៏គេមានបញ្ហានិយាយមិនច្បាស់ដោយសារគេមានឯកសារដើមរបស់គេរស់នៅយូ មានឯកសារ ទទួលស្គាល់ពីសង្គមចាស់ក៏ខាងអត្តសញ្ញាណប័ណ្ណផ្តល់ជូនដែរ ព្រោះគេគ្រប់គ្រាន់ទៅតាមផ្លូវច្បាប់ ។ ហើយបើសិនជាអ្នកថ្មីៗនេះមានផ្តល់ខុសដោយ អំពើអ្វីមួយនោះ នឹងមានការដកហូតយកវិញទាំងអស់ សព្វថ្ងៃនេះមានអ្នកផ្តល់ខុសខ្លះគឺមិនបានចែកឱ្យទេ ។ ជនបរទេសខ្លះនោះ ចូលសញ្ជាតិ មានសញ្ជាតិតួបណើកម្មអ្នកនោះ មិនចេះខ្មែរទេ និយាយមិនច្បាស់ទេ ប៉ុន្តែត្រូវតែផ្តល់ជូនគេដើម្បីឱ្យដឹងថា គេចូលសញ្ជាតិខ្មែរហើយមានព្រះរាជក្រឹត្យ ហត្ថលេខា ពីព្រះករុណាហើយ គឺត្រូវផ្តល់ជូន។

បញ្ហាការសំលាប់មន្ត្រីគណបកសនយោបាយ កន្លងមកលោកបានដឹងច្បាស់ណាស់ថា ប៉ូលិសមុននឹងថាទាល់តែចាប់សាម៉ីខ្លួនបាន ហើយវែកញែក ច្បាស់លាស់បានប្រកាស មិនមែនគ្រាន់តែសំលាប់ភ្លាមប្រកាសថាជារឿងនយោបាយទេ ។

បញ្ហារឿងកាំភ្លើងលោកទទួលស្គាល់ព្រោះប្រទេសមានច្បាប់មានទំលាប់ត្រឹមត្រូវ តែបុគ្គលទេប្រើប្រាស់មានអត្តចារឹកមិនល្អ ហើយមិនគោរពច្បាប់ហើយធ្វើអំពើរផ្តេសផ្តាស ហើយច្បាប់របស់កម្ពុជាគឺមានច្បាប់ប្រើប្រាស់អាវុធជាតិផ្ទុះនេះ។

**កញ្ញា ហេង ចន្ទី** ជំនួយការកម្មវិធី អង្គការជនពិការកម្ពុជា ដោយនៅក្នុងជំពូកទី៨ បង្ហាញពីការឃោសនាក្នុងការបោះឆ្នោត ដែលមានចំណុចជាច្រើន ដូចជា ផ្សព្វផ្សាយតាមឃោសនៈស័ព្ទ និងផ្សព្វផ្សាយដោយការស្រែកជាពាក្យស្លោកខ្លីៗ ។ កញ្ញាបានសួរបញ្ជាក់ទៅខាង ឯកឧត្តមអគ្គគជប ចំពោះការផ្សព្វផ្សាយជាភាសាសញ្ញាសំរាប់ជនពិការគថ្លង់ មកដល់ពេលនេះតើមានដំណើរយ៉ាងម៉េច ?។ កញ្ញាបានលើកឡើងនូវចំណុចមួយចំនួន **ទី១** ដើម្បីធ្វើការផ្សព្វផ្សាយពីបញ្ហាជនពិការ និងព័ត៌មានផ្សេងៗ លោកប្រធានអង្គការជនពិការកម្ពុជា និងអង្គការអភិវឌ្ឍន៍លើវិស័យពិការភាព (ADD) ចង់ចូលរួមប្រជុំនៅ NEC ដែលតែងតែធ្វើជារៀងរាល់ខែ ។ កញ្ញាក៏បានសុំឱ្យ គជប ចេញសេចក្តីប្រកាសមួយដែល ផ្សព្វផ្សាយដល់ជនពិការនៅតាមខេត្តបានចូលរួមប្រជុំនៅក្នុង PEC និង CEC ផងដែរ ។

**ទី២** ការចូលបំរើការងារនៅក្នុង គជប នៅពេលបោះឆ្នោតដូចខាងខុមប្រៀលលើកឡើងថាមានការស៊ូកប៉ាន់ កញ្ញាយល់ស្របនិងចំណុចនេះ ។ ចំនុចមួយទៀតគេទាមទារឱ្យមានបទពិសោធន៍អ្នកថ្មីៗ ដែលមិនមាន បទពិសោធន៍គឺមិនយកទេ ហើយឯកឧត្តមក៏បានបញ្ជាក់ដែរថាឥឡូវនេះយក ៣០% ចំពោះអ្នកថ្មី អញ្ចឹងសូមឱ្យ៣០%នេះមានបញ្ច្រៀបជនពិការ ដែលមានសមត្ថភាពចូលរួមផងដែរ ។

**ទី៣** ចំពោះសន្លឹកឆ្នោតជនពិការភ្នែក ដោយមានជនពិការភ្នែកបានលើកជាសំណូមពរសូមឱ្យ គជប ជួយធ្វើម៉េចឱ្យមានសន្លឹកឆ្នោតដល់ពួកគាត់ដើម្បីចូលរួមបោះឆ្នោត ព្រោះពេលគាត់បោះឆ្នោតរាល់ដងមាននីតិជនជួយគាត់ អញ្ចឹងមានន័យថាមិនមែនជា ការសំងាត់ទេ ។ នេះជាបញ្ហាដែលគាត់លើកឡើងនៅថ្ងៃទី០៣ធ្នូសិទ្ធិរបស់ជនពិការផ្ទាល់ ។

**ទី៤** ទីតាំងការិយាល័យបោះឆ្នោត ដោយមានសំណូមពរពីបងប្អូនជនពិការនៅខេត្តព្រៃវែង ដែលថាភាគច្រើនដាក់នៅលើវិហារមានកាំជណ្តើរខ្ពស់ៗគាត់មិនអាចចូលបោះឆ្នោតបាន ។ កញ្ញាសូមឱ្យមានការិយាល័យនៅកន្លែងទាប មានជំរាលសំរាប់ជនពិការ ធ្វើដូចនេះសំលេងសន្លឹកឆ្នោតនឹងអាចកើនឡើង ព្រោះមានការចូលរួមពីជនពិការច្រើន ។

**លោក សយ សុខន** ប្រធានអង្គការជនពិការជួយខ្លួនឯង ស្រុកបាធាយ បានមានប្រសាសន៍ពាក់ព័ន្ធនិងរឿងអត្តសញ្ញាណប័ណ្ណ គឺជនពិការភាគច្រើនមិនបានទទួលអត្តសញ្ញាណប័ណ្ណទេ ។ មូលហេតុ **ទី១** អ្នកខ្លះពិការជើង ហើយនៅសាលាឃុំមិនមានជំរាលសំរាប់ជនពិការទេ។ **ទី២** ពាក់ព័ន្ធនិងថវិការ គឺពេលទៅតំរូវតែឱ្យលុយតែម្តង ភាគច្រើនថាអនុគ្រោះ ប៉ុន្តែការអនុគ្រោះ ២ ០០០ រៀល ហើយគាត់ចំណាយទៅថតអត្តសញ្ញាណប័ណ្ណដើម្បីចូលរួមនៅក្នុងសង្គម គាត់ចង់ខ្លាំងមែនទែន ។ ថវិការរបស់គាត់២០០០-៣០០០រៀល មិនមែនជាការយកទេ ជាការជួយរំលែក ប៉ុន្តែការជួយ

វិលែកនោះហាក់ដូចជាធ្ងន់ធ្ងរបន្តិចសំរាប់ជនពិការ ព្រោះជនពិការ ជាជនដែលក្រីក្រនិងងាយរងគ្រោះជាទីបំផុត ។ លោកក៏បានសំណូមពរទៅខាងក្រសួងមហាផ្ទៃ សូមផ្តល់ការអនុគ្រោះដល់ជនពិការឱ្យបានទាបបំផុតនៅក្នុងចំនុចណាមួយតាមដែរអាចធ្វើទៅបាន ។

ពាក់ព័ន្ធនិងការិយាល័យបោះឆ្នោតចល័ត ដោយជនពិការមានចំណុចខ្លះដែលគាត់មិនអាចទៅបោះឆ្នោតបាន **ទី១** អត់មានជំរាល **ទី២** ជនពិការភ្នែកគាត់មិនអាចគូសលើសន្លឹកឆ្នោតដែលគាត់ពេញចិត្តដោយខ្លួនឯង មានអ្នកជួយ នេះមិនមែនជាការសំងាត់ទេ ។ **ទី៣** ពាក់ព័ន្ធនិងចាស់ជរា ស្ត្រីមានផ្ទៃពោះឆ្លងទន្លេ ជនពិការដែលធ្ងន់ធរ គាត់មិនបានទៅបោះឆ្នោតទេ ដូច្នេះសូមឱ្យ គជប ធ្វើយ៉ាងម៉េចឱ្យមានការិយាល័យបោះឆ្នោតចល័តមួយនៅតាមភូមិឃុំសង្កាត់តែម្តង ។ នីតិវិធី គឺគ្រាន់តែសុំព័ត៌មានពីមេឃុំ មេភូមិ សូមឱ្យផ្តល់ចំនួនអ្នកដែលមិនអាចធ្វើដំណើរទៅបោះឆ្នោតបានហើយគាត់មានអត្តសញ្ញាណប័ណ្ណគ្រប់គ្រាន់ ។

**ឯកឧត្តម ទេព នីថា** ដោយបានទទួលសំណូមពរកាលពីប្រជុំលើកមុន ចំពោះការផ្សព្វផ្សាយ គជប បានចាត់ចែងធ្វើឱ្យមានភាសារគរសំរាប់ស្ពតមួយចំនួនដែលអាចធ្វើទាន់ ។ ដោយឡែកទាក់ទងនិងការឃោសនារបស់គណបក្ស គជប មិនអាចធ្វើបានទេ ព្រោះមកដល់ពេលនេះ គជប មិនទាន់បានរៀបចំកម្មវិធីនោះ ហើយមិនដឹងថាគណបក្សនយោបាយគាត់និយាយអ្វីខ្លះ អញ្ចឹងបញ្ហារៀបចំជាភាសារបកប្រែផ្ទាល់ៗ គជប ធ្វើមិនអាចធ្វើកើតទេ ។ ដូច្នេះបញ្ហាស្ពតរបស់គណបក្សនយោបាយ គជប ធ្វើមិនអាចធ្វើបានទេ ប៉ុន្តែស្ពតអប់រំរបស់ គជប ទាក់ទងទៅនិងការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋយើងអាចធ្វើបានក្នុងក៏រិតមួយ ។

ចំពោះការចូលរួមប្រជុំរបស់អង្គការជនពិការនៅ គជប នៅខេត្តមិនមានបញ្ហាទេ ។ កន្លងមក គជប ស្គាល់អង្គការណាមួយច្បាស់លាស់ធ្លាប់មានទំនាក់ទំនង គជប ធ្វើលិខិតអញ្ជើញ ប៉ុន្តែអង្គការដែល គជប មិនបានធ្វើការអញ្ជើញនោះក៏អាចទៅចូលរួមបានព្រោះ គជប បានធ្វើសេចក្តីអំពាវនាវទូទៅមួយ ដោយជូនដំណឹងមុន២-៣ថ្ងៃ នៃកិច្ចប្រជុំ ។ សំខាន់ គជប ធ្វើលិខិតទៅលើអង្គការណាដែលបានដាក់បញ្ជីសង្កេតការណ៍នៅ គជប រួចហើយ ចំពោះអង្គការមួយចំនួនដែលមិនទាន់បានដាក់បញ្ជីសង្កេតការណ៍នៅ គជប គឺមានជាលិខិតអញ្ជើញជាទូទៅ ។ ដូច្នេះបើសិនជាមានព័ត៌មានពីការប្រជុំរបស់ គជប អាចទៅចូលរួមប្រជុំបាន គជប មិនមានផែកលិខិតអញ្ជើញទេ ។ បើសិនជាមានព័ត៌មានមកប្រជុំជាប់ លើកក្រោយ គជប អាចធ្វើលិខិតអញ្ជើញបាន ដោយមានអាសយដ្ឋានរួចហើយ ។ នៅថ្នាក់ខេត្តក៏ធ្វើបែបនេះដែរ គជប នឹងជូនដំណឹងទៅខេត្តបន្ត ទៀត ។

ចំពោះទីតាំងការិយាល័យបោះឆ្នោតនៅកន្លែងខ្ពស់ ដូចឯកឧត្តមបានជម្រាបរួចហើយ គជប មិនអាចដោះស្រាយចេញ ព្រោះទីតាំងការិយាល័យមិនមែនជាកន្លែងអចិន្ត្រៃយ៍របស់ គជប ទេ គឺ គជប ខ្ចីគេសំរាប់ធ្វើការបោះឆ្នោត ២ថ្ងៃ ។ ចំពោះកន្លែងដែលនៅវិហារនោះ បានន័យថាកន្លែងនោះមិនមានសាលាទើបគេធ្វើនៅទីនោះ នេះជាការលំបាកណាស់ ។ នៅក្នុងនីតិ គជប ក៏មានការបង្ករលក្ខណៈងាយស្រួលដល់ជនពិការដែរ ប្រសិនបើអាចធ្វើបាន គជប និងនឹងរំលឹកទៀត ដើម្បីឱ្យជួយលើករទេះកង់ឡើងទៅលើ តែបើឱ្យរៀបចំការិយាល័យនៅផ្ទាល់ដីទាំងអស់គឺលទ្ធភាពរបស់ គជប នៅមានក៏រិតទាបណាស់ ។

ចំពោះសន្លឹកឆ្នោតសំរាប់ជនពិការ គជប គ្មានគំរោងធ្វើទេឯកឧត្តមសូមអធ្យាស្រ័យ សូមឱ្យអនុវត្តន៍នីតិវិធីចាស់សិន គឺឱ្យមានជាអ្នកជូនទៅបោះឆ្នោត បើអាចបាន គជប នឹងធ្វើនៅឆ្នាំ ២០០៨ ។ ចំពោះការិយាល័យបោះឆ្នោតចល័ត ច្បាប់មិនតំរូវឱ្យមានទេ គជប មិនអាចធ្វើបានទេ លើកលែងតែច្បាប់តំរូវឱ្យមានទើបអាចធ្វើបាន ។

សំរាប់ការចូលបំរើធ្វើការងារ កាលដែលថាមិនយកបទពិសោធន៏ ឯកឧត្តមចង់និយាយថាមិនមែនមិនយកបទពិសោធន៏ទេ គឺយកបទពិសោធន៏ តែមិនមែនយកបទពិសោធន៏បោះឆ្នោតទេ ឧទាហរណ៍យើងជ្រើសរើសលេខាធិការ យើងទាមទារបទពិសោធន៏របស់ជំនាញគាត់ខាងលេខាធិការ បើសិនគាត់មានបទពិសោធន៏ហើយ យើងមើលបទពិសោធន៏បោះឆ្នោតមួយទៀត ។ អញ្ចឹងបទពិសោធន៏នេះមិនសំដៅលើបទពិសោធន៏លើការបោះឆ្នោតទេ គឺបទពិសោធន៏ក្នុងការធ្វើការងារ ។ មូលហេតុដែល គជប រើសអ្នកដែលមានបទពិសោធន៏ ព្រោះការងារបោះឆ្នោតជាការងាររយៈ

ពេលខ្លី ដែលមានការបណ្តុះបណ្តាលរយៈពេល១-២ថ្ងៃ បើរើសអ្នកដែលមិនមានបទពិសោធន៍ក្នុងការធ្វើការសោះ ហើយបណ្តុះបណ្តាលរយៈ ពេលខ្លី នាំឱ្យធ្វើការមិនកើត នាំឱ្យបរាជ័យ ។ គជប មិនមែនរើសអើងទេ ដោយសារការងារខ្លីនាំឱ្យ គជប ទាមទារលក្ខខ័ណ្ឌ មួយខ្ពស់ដែរ ។

ឯកឧត្តមបានជំរាបពីនីតិវិធីសំខាន់ៗនៃការឃោសនាបោះឆ្នោតដែល គជប បានត្រៀម ក៏ដូចជាព័ត៌មានទាក់ទងនិងបញ្ហានេះផងដែរ

**ទី១** នីតិវិធី គជប បានចែកជូនគ្រប់គណបក្សរួចហើយ ទោះបី គជប មិនទាន់បានធ្វើការបណ្តុះបណ្តាលជាផ្លូវការក៏ដោយ ប៉ុន្តែយើងបានជជែកគ្នានៅលើនីតិវិធីនៃការឃោសនាបោះឆ្នោតតាំងពីមុនពេលដែលនីតិវិធីត្រូវបាន គជប អនុម័ត ។ សេចក្តីព្រាងនីតិវិធីនេះ គជប បានជូនទៅគ្រប់គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដោយបានជជែកគ្នាច្រើនលើកលើឯកសារនេះ ។ អ្វីដែលសំខាន់យើងជជែកគ្នាលើចំណុចមួយចំនួន តែដល់ការសំរេចរបស់ គជប លើនីតិវិធីគឺមិនមែនគ្រប់ចំណុចទាំងអស់ដែលបានជជែកគ្នាទេ ។

**ទី២** ការឃោសនាបោះឆ្នោតមានរយៈពេល ១៥ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី ១៦-៣០ ខែមិនា ។ ថ្ងៃ៣១ ខែមិនា មិនអនុញ្ញាតឱ្យមានការឃោសនាទេ គឺជាថ្ងៃស ។

សំរាប់ការរៀបចំរបស់ គជប **ទី១** កម្មវិធីស្មើភាព ដែល គជប បានសរសេរនៅក្នុងនីតិវិធី គជប មិនទាន់បានសំរេចច្បាស់លាស់ថា ត្រូវស្មើភាពក្នុងកំរិតណាទេ ព្រោះបើយើងពិនិត្យមើលច្បាប់បោះឆ្នោតតំណាងរាស្ត្របានកំរិតថា គណបក្សនយោបាយនីមួយៗត្រូវដាក់បញ្ជីបេក្ខជនយ៉ាងតិចប៉ុន្មានខេត្តក្រុង ប៉ុន្មានមណ្ឌល ។ ឧទាហរណ៍ ១ភាគ៣ នៃមណ្ឌល អញ្ចឹង គជប ឱ្យកម្មវិធីស្មើភាពនៅក្នុងប្រព័ន្ធផ្សព្វផ្សាយបានសមហេតុផល ។ ការបោះឆ្នោតឃុំច្បាប់មិនមានកំរិតទេ ឧទាហរណ៍ ឆ្នាំ ២០០២ មានគណបក្សមួយគាត់ដាក់តែមួយឃុំសង្កាត់ ដែលមានបេក្ខជន ១៨នាក់ អញ្ចឹងបើឱ្យរយៈឃោសនាតាមប្រព័ន្ធផ្សព្វផ្សាយ ១០នាទី ស្មើគណបក្សដែលដាក់បញ្ជីបេក្ខជន ១៦២១ឃុំសង្កាត់ តើសមហេតុផលដែលទេ? ។ បញ្ហានេះ គជប មិនទាន់បានសំរេចទេ តែបានផ្តល់ព័ត៌មានទៅគណបក្សនយោបាយរួចហើយ នៅពេលគណបក្សនយោបាយចុះបញ្ជីបេក្ខជនហើយ គជប នឹងអញ្ជើញតំណាងគណបក្សដែលចុះបញ្ជីបេក្ខជនដើម្បីធ្វើការពិភាក្សាលើចំណុចនេះ ។ ដោយឡែក គជប បានចេញសៀវភៅនេះ ដើម្បីជូនគណបក្សនយោបាយក៏ដូចជាអ្នកតំណាងបំពេញការងារឱ្យ គជប គណៈកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត ។

ចំពោះការសំរបសំរួលនៅថ្នាក់ឃុំសង្កាត់ ដោយសារជាការបោះឆ្នោតឃុំសង្កាត់ ការងារឃោសនាសំខាន់នៅឃុំសង្កាត់ អ្នកសំរបសំរួលនៅទីនោះ គឺគណៈកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត ។ គណៈកម្មាការនេះក្រោយពេលដែលចុះបញ្ជីបេក្ខជនហើយនឹងមានការប្រជុំជាប្រចាំ សប្តាហ៍ជាមួយភាគី ជាពិសេសជាមួយគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរនៅមូលដ្ឋាន ដើម្បី**ទី១** ការងារសន្តិសុខ **ទី២** ផ្លាស់ប្តូរព័ត៌មានទាក់ទងនិងការបោះឆ្នោត ។ ការសំខាន់នៅក្នុងតំណាក់កាលដែលបណ្តុះបណ្តាលលើកនេះ គឺទាក់ទងនិងការឃោសនាបោះឆ្នោត ព្រោះគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតជាអ្នកសំរបសំរួល ។ គណបក្សនយោបាយចង់ធ្វើការឃោសនាបោះឆ្នោតនៅឃុំសង្កាត់ គឺជូនព័ត៌មានទៅគណៈកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត ដើម្បីពិនិត្យពេលវេលា និងទីកន្លែង ដើម្បីបញ្ចៀសការត្រួតគ្នានៅទីកន្លែងតែមួយ លើផ្លូវតែមួយ ក្នុងពេលតែមួយ ។ ការងារនេះផ្តល់អាទិភាពទៅដល់អ្នកជូនដំណឹងមុនក្រោយ ។ ការសំរបសំរួលនេះ ទី១ ដោយផ្ទាល់ជាមួយគណបក្សដែលពាក់ព័ន្ធ ទី២ តាមរយៈការប្រជុំ ។ លើកនេះយើងឱ្យគណៈកម្មាការឃុំសង្កាត់ធ្វើការប្រជុំក្នុងករណីមានការបន្ទាន់អាចកោះប្រជុំបានភ្លាមៗ ទើបការដាក់ពាក្យរបស់គណបក្សនយោបាយចុះបញ្ជីនៅឃុំសង្កាត់ ទាមទារឱ្យមានអាសយដ្ឋាន ទីស្នាក់ការនៅឃុំសង្កាត់ និងអ្នកតំណាងគណបក្សដើម្បីទំនាក់ ទំនងទៅឃុំសង្កាត់ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ។ គណបក្សនីមួយៗក្នុងករណីមានបញ្ហានៅឃុំសង្កាត់ ហើយដោះស្រាយមិនបានអាចទាក់ទងផ្ទាល់មកខេត្តដើម្បីសំរបសំរួល បើសិននៅតែដោះស្រាយមិនចេញអាចទាក់ទងមក គជប តែម្តង ។

បើពិនិត្យនីតិទាំងស្រុង គឺមិនខុសពីការឃោសនាបោះឆ្នោតមុនៗទេ ហើយគណបក្សនយោបាយបច្ចុប្បន្នក៏មានកំរិតនៃការយល់ដឹងខ្ពស់ទាំងមូលដ្ឋានច្បាប់ ទាំងការអនុវត្តន៍ជាក់ស្តែង ហើយក៏មានបទពិសោធន៍ ។ ម្យ៉ាងទៀតឆ្លងកាត់ការបោះឆ្នោតក្រោយៗនេះ គណបក្សទោះបីជាប់ឆ្នោត មិនជាប់ឆ្នោតក្តី គឺបានរួមសហការណ៍អង្គុយប្រជុំទល់មុខគ្នា ដោយបានជជែកគ្នាត្រង់ទៅត្រង់មក ហើយដឹងបញ្ហាទាំងអស់គ្នា ។ គោលការណ៍

ណែនាំជាទូទៅរបស់ គជប តែងលើកទឹកចិត្តឱ្យមានការយោគយល់ ការសហការ ការគោរពគ្នាទៅវិញទៅមក នេះជាមូលដ្ឋានសំខាន់ដែលជំរុញឱ្យការឃោសនាបោះឆ្នោតប្រព្រឹត្តិទៅបានល្អ ។

**លោក សំ គន្ធាមី** អ្នកសំរបសំរួលគណៈកម្មាការនិកហ្វិច ពាក់ព័ន្ធនិងការឃោសនាបោះឆ្នោត លោកសូមឱ្យឯកឧត្តមអគ្គបំភ្លឺនៅក្នុងជំពូកទី ៨ ប្រការ ៨.៤ ត្រង់ចំណុចការដឹកជញ្ជូនអ្នកបោះឆ្នោត ទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនេះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ ។ សូមឯកឧត្តមបញ្ជាក់ត្រង់ចំណុចមិនមានទ្រង់ទ្រាយធំ ថាយ៉ាងម៉េច។ មួយទៀតនៅប្រការ ៨.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបានកំណត់ដូចជា រថយន្តទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ផ្លាកសញ្ញារាជការ រដ្ឋ នបខម និងរាជរដ្ឋាភិបាល ។ លោកចង់បញ្ជាក់ថា ចំពោះឡានដែលមានផ្លាកលេខរដ្ឋសភា រាជវាំង តើផ្លាកលេខនេះអាចប្រើបាន ឬហាមតែប៉ុន្នានេះទេ ។

**ឯកឧត្តម កែ ប៊ុនខៀង** អនុប្រធានគណៈឃោនាអប់រំ គណកម្មាធិការ គណបក្សប្រជាជន បានសួរបញ្ជាក់ពីបញ្ហាមួយចំនួនដែលអាចកើតមាននៅក្នុងដំណាក់កាលនៃយុទ្ធនាការឃោសនា ។ កន្លងមកឯកឧត្តមឃើញមានកម្មវិធីមួយចំនួនដែលហាក់ដូចជាមិនបានកំណត់នៅក្នុងនីតិវិធីនេះទេ ។ ឯកឧត្តមឃើញមានសង្គមស៊ីវិលមួយចំនួននឹងត្រៀមរៀបចំកម្មវិធីមួយចំនួន ឯកឧត្តមចង់ដឹងអំពីបញ្ហានេះឱ្យច្បាស់ ឧទាហរណ៍ តើកម្មវិធីស្មើភាពនៅអង្គការមិនមែនរដ្ឋាភិបាលរៀបចំ ទទួលការយល់ព្រមពី គជប ឬគ្រាន់តែជូនដំណឹង ។ ជាក់ស្តែងកន្លងមកគាត់រៀបចំវេទិការពិភាក្សាបេក្ខជននៅតាមមណ្ឌល នៅឃុំសង្កាត់ទូទាំងប្រទេស ឧទាហរណ៍ បោះឆ្នោតអាណត្តិទី១ គាត់រៀបចំ ៦ឃុំសង្កាត់ ប៉ុន្តែពេលនោះ គជប ទៅតាមរហូតហើយយកមកផ្សព្វផ្សាយនៅទូរទស្សន៍ជាតិ ។

តាមដែលឯកឧត្តមដឹង មិនដឹងថា គជប ដឹងដែរឬទេ ឥឡូវគាត់រៀបចំ ៣០មណ្ឌល បើយើងពិនិត្យនៅក្នុងនេះមិនមានទេ ប៉ុន្តែឯកឧត្តមគិតថា គជប នឹងអនុញ្ញាតឱ្យធ្វើ ។ ឯកឧត្តមសូមឱ្យដឹងថា តើអង្គការមិនមែនរដ្ឋាភិបាលដែលត្រៀមធ្វើនេះ មាននៅកន្លែងណាខ្លះ អាចជូនដំណឹងមុនបានទេ ព្រោះកន្លងមកមាន មិននិយាយអីទេស្រាប់តែដល់ថ្ងៃគាត់ធ្វើ ហើយអញ្ជើញតំណាងគណបក្សឱ្យចូលរួមតែម្តង ។ នេះជាបញ្ហាដែលឯកឧត្តមគិតប្រការជាមុន ពីភាពអព្យាក្រឹត្យរបស់អង្គការមិនមែនរដ្ឋាភិបាល ។ បើធ្វើត្រូវជូនដំណឹងពីគោលដៅ ខ្លឹមសារមុន សំរាប់គ្រប់គណបក្សនយោបាយដើម្បីកុំឱ្យខុសច្បាប់ នីតិវិធី ។ សំរាប់គណបក្សប្រជាជនកម្ពុជាឱ្យតែមានការជូនដំណឹងត្រឹមត្រូវ ស្របតាមច្បាប់ តាមនីតិ វិធីបទបញ្ជា និងការរៀបចំឱ្យបានត្រឹមត្រូវ ស្មើភាព មានការយល់ព្រមពី គជប ថាស្របច្បាប់ គណបក្សប្រជាជននឹងចូលរួម ។ ជៀសវាងការធ្វើទៅមិនត្រឹមត្រូវ ព្រោះបើរៀបចំឡើងមិនមានការទទួលស្គាល់ពី គជប ពីគណៈកម្មាការបោះឆ្នោតឃុំសង្កាត់ បើមានបញ្ហាកើតឡើង តើអ្នកណាជាអ្នក ទទួលខុសត្រូវ ។

ពាក់ព័ន្ធនិងការយកមកផ្សព្វផ្សាយ តើ គជប មានការត្រួតពិនិត្យ ឬក៏យកមកជួលបណ្តាញផ្សព្វផ្សាយ ហើយគេផ្សាយយ៉ាងម៉េចក៏បាន សូមឯកឧត្តមអគ្គ គជប បញ្ជាក់ពីបញ្ហានេះ ។ ឯកឧត្តមយល់ថាបញ្ហានេះមានគណៈកម្មាការសំរបសំរួលកម្មវិធីស្មើភាព ដែលនឹងប្រជុំជាមួយគណបក្សនយោបាយទាំងអស់ ។

**លោក ម៉ា សុផល** បានធ្វើការចាប់អារម្មណ៍រួមពាក់ព័ន្ធនិងដំណើរការឃោសនារបស់គណបក្សនយោបាយ ជាពិសេសពាក់ព័ន្ធនិងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ កន្លងមកបានផ្សព្វផ្សាយតែសកម្មភាពរបស់គណបក្សនយោបាយមួយ ហើយគណបក្សនយោបាយនោះចេញទាំងផ្លាកសញ្ញា ចេញទាំងសកម្មភាព ហើយគណបក្សនយោបាយផ្សេងៗទៀតមិនត្រូវបានឃើញនៅក្នុងប្រព័ន្ធ ផ្សព្វផ្សាយរបស់រដ្ឋទេ ។ នេះជាបញ្ហាកង្វល់មួយដែលខាងខុមហ្វ្រែលសូមសំណូមពរទៅ គជប ធ្វើម៉េចប្រើប្រាស់នៅសមត្ថកិច្ចរបស់ខ្លួននៅក្នុងការសហការណ៍ជាមួយក្រសួងព័ត៌មាន ដូចដែល គជប ធ្លាប់បានធ្វើកន្លងមក ។ បើជ្រុលឱ្យគាត់ផ្សព្វផ្សាយមុនដំណាក់កាលឃោសនាហើយ គជប អាចរៀបចំធ្វើយ៉ាងម៉េចសូមទូរទស្សន៍ វិទ្យុរដ្ឋ បានផ្សព្វផ្សាយសកម្មភាពរបស់គណបក្សផ្សេងៗផង ដើម្បីកុំឱ្យអ្នកបោះឆ្នោតទទួលបានព័ត៌មានតែម្ខាង ។

ពាក់ព័ន្ធនិងកម្មវិធីស្មើភាព ខ្ញុំប្រហែលធ្លាប់បានលើករួចហើយសូមឱ្យបានស្មើភាពគ្នា ។ លោកមិនជឿថាមានគណបក្សនយោបាយមួយដាក់បេក្ខជនឈរតែមួយឃុំ សំរាប់ការបោះឆ្នោតឃុំ ។ ឆ្លៀតឱកាសនេះដែរលោកសូមកោតសរសើរចំពោះគណបក្សប្រជាធិបតេយ្យខ្មែរ របស់ ឯកឧត្តម អ៊ុក ភូរិ ខំតស៊ូខ្លាំងណាស់ ទោះបីជាបានតែ១កៅអីក្នុងចំណោម១ម៉ឺនកៅអី គឺនៅតែឮឈ្មោះ ធ្វើសកម្មភាពបន្តទៀត ។ កម្មវិធីផ្សព្វផ្សាយគោលការណ៍របស់គណបក្ស ក៏ដូចជាផែនការអភិវឌ្ឍន៍របស់ខ្លួនដល់ប្រជាពលរដ្ឋ សូមឱ្យស្មើភាពគ្នារវាងគ្រប់គណបក្សដែលចូលរួមប្រកួតក្នុងការបោះឆ្នោត ។ ទោះបី ឧទាហរណ៍នៅភ្នំពេញ គណបក្សមួយដាក់បានតែ ៥០%នៃឃុំ យើងចែកពេលវេលាឱ្យគាត់តែ ៥០%នៃចំនួនរយៈពេលគិតដែលយើងឱ្យ ១០០%ទៅគណបក្សមួយ ប៉ុន្តែឱ្យគាត់មើលយ៉ាងម៉េច បើនៅក្នុងឃុំមួយមានអ្នកគាំទ្រគណបក្សមួយហ្នឹងច្រើនដែរ ស្រាប់តែគាត់អង្គុយមើលទៅឃើញគណបក្សមួយបាន ១០នាទី ហើយគណបក្សមួយទៀតបាន ៥នាទី ។ អញ្ចឹងការខិតខំតាមដានស្វែងយល់ពីកម្មវិធីនយោបាយគណបក្សរបស់គាត់ខ្លី ធ្វើឱ្យការចង់ដឹងចង់យល់ពីផែនការអភិវឌ្ឍន៍របស់គណបក្សនយោបាយមួយតិចជាងគណបក្សនយោបាយមួយទៀត ។

**កញ្ញា ឆន សុខា** ជំនួយការកម្មវិធីនៃ វិទ្យាស្ថានសាធារណៈរដ្ឋអន្តរជាតិ IRI ទាក់ទងនិងប្រព័ន្ធផ្សព្វផ្សាយកញ្ញាឯកភាពទៅនិងអ្វីដែលខាងខ្ញុំប្រហែលបានលើកឡើង ឃើញថាប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដូចជាការសំដែងឈុតឆាកខ្លីៗ ឬក្រុមកំប្លែង ច្រើនតែលេងលំអៀងទៅខាងគណបក្សកាន់អំណាច ។ កញ្ញាមិនដឹងថាតើខាងក្រសួងព័ត៌មានបានត្រួតពិនិត្យឬយ៉ាងម៉េចទេ ព្រោះធម្មតាការសំដែងឆាកនៅតាមកញ្ចក់ទូរទស្សន៍ តែងតែមានការត្រួតពិនិត្យពីក្រសួងព័ត៌មាន ។

ទាក់ទងនិងការធ្វើវេទិការផ្សេងៗរបស់ NGO នៅក្នុងកំឡុងពេលដែលឃោសនា ទាក់ទងនិងការជូនដំណឹង កន្លងមកពេលដែលជូនដំណឹងពេលដែលសុំទៅ គជប ហើយ គជប ប្រាប់ថាត្រូវសុំទៅអាជ្ញាធរ កញ្ញាចង់បានការសំរេចមួយឱ្យច្បាស់លាស់ថា នៅពេលដែល NGO រៀបចំវេទិការផ្សេងៗ តើការសំរេចឱ្យធ្វើជាការសំរេចរបស់ គជប ឬអាជ្ញាធរ ឬស្ថាប័នណាមួយជាក់លាក់? ។

ទាក់ទងនិងខាងគណបក្សប្រជាជនដែលបានលើកឡើងថាជួលកាលខាង NGOធ្វើឡើង ដោយមិនបានជូនដំណឹងទៅគាត់ គ្រាន់តែអញ្ជើញកន្លងមកយើងធ្វើអញ្ចឹងមែន ព្រោះសំខាន់យើងជូនដំណឹងទៅអាជ្ញាធរ ឬ គជប ដែលសំរេចថាឱ្យធ្វើឬមិនឱ្យធ្វើ ហើយខាងគណបក្សអាចអញ្ជើញមួយសប្តាហ៍មុន ឬ១០ថ្ងៃមុនទៅតាមកន្លែងរបស់ NGO ដែលចង់ធ្វើ ជួនកាលមានរយៈពេលខ្លី ជួនកាលរយៈពេលវែង យើងមិនដឹងថានីតិវិធីរបស់គាត់ធ្វើយ៉ាងម៉េចទេ ។ តើយើងត្រូវធ្វើលក្ខណៈយ៉ាងម៉េចដើម្បីអញ្ជើញខាងគណបក្សប្រជាជនឱ្យបានចូលរួម សូមឱ្យកំណត់ឱ្យបានច្បាស់លាស់ ហើយទៅតាមនីតិវិធីរបស់ គជប ផងដែរ ។

**លោក ឌី ណាសាគុណ** ទាក់ទងនិងការឃោសនាបោះឆ្នោត គណបក្សសមរង្ស៊ី នៅតែទទូចដដែល ទាក់ទងនិងសម្ភារៈសំរាប់អ្នកបោះឆ្នោត ហើយអាចទាក់ទងនិងសន្លឹកឆ្នោត ។ សូមឱ្យ គជប ដែលជាអ្នកធ្វើសន្លឹកឆ្នោតមានការដាក់ដេញថ្លៃឱ្យបានត្រឹមត្រូវ ហើយសន្លឹកឆ្នោតក៏ត្រូវធ្វើឱ្យមានស្តង់ដារមួយទទួលស្គាល់ដោយអន្តរជាតិ ។ ចំពោះការដាក់ដេញថ្លៃ ប្រទេសណាធ្វើសូមជូនដំណឹងទៅគ្រប់បណ្តាញគណបក្ស ក៏ដូចជា NGO នៅក្នុងប្រទេសឱ្យបានច្បាស់លាស់ ។ ការដេញថ្លៃមិនមែនចេះតែសរសេរនៅក្នុងលិខិតទេ គឺឱ្យមានការស៊ើបអង្កេតថា ការដេញថ្លៃទៅបាននៅក្រុមហ៊ុនណាមួយហ្នឹង តើក្រុមហ៊ុនមានពាក់ព័ន្ធនិង គជប ឬជាអាជ្ញាធរ ឬប្រភេទណាមួយដែលអាចថាជាបក្សពួក ។ លោកសូមឱ្យមានការលម្អិតនៅក្នុងរឿងនេះ ។

ទាក់ទងនិងការឃោសនាផ្សព្វផ្សាយ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ទទក ដូចជាប្រជុំរដ្ឋសភា លោកតែងតែសង្កេតឃើញខាងមេគណបក្សដែលបានឡើងនិយាយ ជាពិសេសគណបក្សសមរង្ស៊ី ការចាក់ផ្សាយមិនដឹងជាបច្ចេកទេស ឬមានចេតនាទេ គឺមានឮសំឡេង តែមិនមានរូប មួយស្របក់បានចេញជារូប ។ ជៀសវាងការមានចេតនាបំបាំងរូប ដែលប្រជាពលរដ្ឋចង់ឃើញមុខប្រធានគណបក្ស លោកបានសំណូមពរថា បើមានការចាក់ផ្សាយហើយបើប្រធានបក្សនិយាយហើយសូមឱ្យមានរូប និងសំឡេងទៅជាមួយគ្នា ។

លោកក៏សូមឱ្យ គជប និងក្រសួងមហាផ្ទៃធ្វើលិខិតជាលាយល័ក្ខអក្សរមួយឱ្យបានច្បាស់ជូនទៅអាជ្ញាធរថា ការទៅសុំច្បាប់ ឬជូនដំណឹងត្រូវមានលក្ខខ័ណ្ឌយ៉ាងម៉េច ដើម្បីឱ្យលិខិតលាយលក្ខ័អក្សរជូនទៅដល់អាជ្ញាធរ ។ ជៀសវាងអាជ្ញាធរមិនបានឃើញដំណឹង នាំឱ្យគាត់មានការចង្អៀតចង្អល់ក្នុងការធ្វើការឃោសនា ។ រឿងនេះអាចការពារ និងកាត់បន្ថយជម្លោះពេលឃោសនាបោះឆ្នោត ។ កន្លងមកគណបក្សសមរង្ស៊ីមានជួបការលំបាក ដោយសុំម្តងថាទៅខាងនេះ ម្តងថាទៅខាងនោះ រុញទៅរុញមក នាំឱ្យពេលវេលាកាន់តែយូរទៅៗ ទាល់តែមានការអន្តរាគមន៍ដល់តំណាងរាស្ត្រ ឬថ្នាក់ដឹកនាំ ទើបអាចសំរួលបាន ។ នេះជាចេតនាដដែលៗ ដែលគណបក្សសមរង្ស៊ីតែងតែជួបប្រទះ ។

ចំពោះពេលយុទ្ធនាការបែងចែករំលែកព័តិមាននៅពេលឃោសនា សូមឱ្យស្មើភាពចំពោះគណបក្សដែលមានអាសនៈនៅឃុំទាំងអស់ ។

**លោកស្រី ពឹង យក់ហៀប** នាយិកា នៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា LAC ទាក់ទងនិងច្បាប់ស្តីពីការឃោសនាបោះឆ្នោត ត្រង់ទំព័រ ៩៩ ប្រការ ៨.១៤ ដែលថា គណបក្សនយោបាយ ឬតំណាងបេក្ខជនដែលប្រព្រឹត្តផ្ទុយនិងប្រការ ៨.១៣ នឹងត្រូវទទួលទោសតាម មាត្រា ១៧៨ថ្មី មាត្រា ១៨១ថ្មី និងមាត្រា ១៨៧ថ្មី នៃ ចបគស ។ លោកស្រីបានមានសំណួរថា ក្នុងសៀវភៅនេះមិនមានបញ្ជាក់ថានៅក្នុងមាត្រានេះត្រូវមានទោសយ៉ាងណាទេ ហើយពាក្យថា ចបគស មានន័យថាយ៉ាងម៉េច? ។ ចំពោះមាត្រា ៨.១៥.១៣ ក៏បានបញ្ជាក់ថា ត្រូវទទួលទោសតាមមាត្រា ១៨៧ថ្មី ។

ចាប់តាំងពីទទួលពាក្យបេក្ខជនដែលត្រូវបោះឆ្នោតមានចំនួនប៉ុន្មាន? នៅក្នុងនោះតើមានបេក្ខនារីចំនួនប៉ុន្មាននាក់? តើខាង គជប មានផែនការយុទ្ធសាស្ត្រ ដើម្បីឃោសនាទាក់ទាញឱ្យបេក្ខនារីមកចុះឈ្មោះ ហើយឈរឈ្មោះជាអ្នកដឹកនាំក្រុមប្រឹក្សាឃុំសង្កាត់ដែរឬយ៉ាងណា? ។

ទាក់ទងនិងខាង UNDP តើមានផែនការយុទ្ធសាស្ត្រយ៉ាងណា ដើម្បីជ្រើសរើសអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក្នុងការជួយធ្វើការជាមួយ គជប ហើយបើជួយត្រូវជួយផ្នែកណាខ្លះ ។ លោកស្រីបានសំណូមថា គជប គួរតែជួយសំរួលដល់និស្សិតដែលគ្មានការងារធ្វើ មានមុខធ្វើការដើម្បីរួមចំណែក និងការអភិវឌ្ឍន៍ប្រទេស ជាពិសេសការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ និងការបោះឆ្នោតទៅអនាគត ។

**លោក ឱក សេរី សោភ័ក្តិ** បានមានប្រសាសន៍ថា ដោយសារខាងតំណាង UNDP មិននៅ លោកបានជំរាបជូនលោកស្រី ពឹង យក់ហៀបថា នៅខបសែលច្រើនលើកហើយ ដែលអង្គប្រជុំតែងតែលើកបញ្ហា ថាដើម្បីឱ្យមានតម្លាភាព ដើម្បីប្រើប្រាស់និស្សិតដែលបញ្ចប់ការសិក្សារួចហើយ ប៉ុន្តែមិន ទាន់បានការងារធ្វើ ហើយចង់បំរើជាតិ បំរើសហគមន៍ ដែលភាគច្រើន ច្រើនតែស្ម័គ្រចិត្ត ។ ដូច្នេះបានជាស្នើឱ្យ គជប ធ្វើការនេះជាមួយនិស្សិត ។ គជប ក៏បានចាប់ផ្តើមធ្វើការរួចហើយជាមួយនិង YCC ដោយពេលដែលយើងចែកប័ណ្ណព័តិមានកាលពីខែសីហា ដោយសារមានចំណុចអវិជ្ជមានខ្លះពីសំណាក់មេភូមិមួយចំនួនតូច ខបសែល បានលើកឡើងថា ដល់ពេលចែកប័ណ្ណព័តិមាននៅខែមិនាខាងមុខនេះ គួរតែបើកដំហរយន្តការចែកប័ណ្ណ ព័តិមានជាលើកទី២ ឱ្យមានតម្លាភាព ដោយប្រើប្រាស់ការចូលរួមរបស់និស្សិត ធ្វើការស្ម័គ្រចិត្តក្នុងការងារនេះ ។ UNDP បានទាក់ទងជាមួយនិងនិកហ្វិចដែរ តែដោយសារនិកហ្វិចជាប់រវល់ ក៏បានទាក់ទងជាមួយ YRDP ហើយក៏បានបន្តទៅ YCC ទៀត ។ ដូចនេះបានឯកឧត្តមអគ្គលេខាធិការ គជប មានប្រសាសន៍ពីគណៈកម្មាការនៅតាម CEC ដែលមានសមាជិកម្នាក់ចូលរួមពីសង្គមស៊ីវិល គឺជានិស្សិត ។

**ឯកឧត្តម អ៊ុក ភូរិ** មានការចាប់អារម្មណ៍ និងមានការគាំទ្រចំពោះការរៀបចំឱ្យមានកម្មវិធីស្មើភាពនៅពេលបោះឆ្នោតឃុំសង្កាត់ ដែលពីមុនមិនដែលមាន ។ ឯកឧត្តមក៏មានការព្រួយបារម្ភថាអាចធ្វើទៅមានភាពអយុត្តិធម៌ច្រើន ព្រោះដូចឯកឧត្តអគ្គលេខាធិការ គជប ថាមិនទាន់សំរេចបានច្បាស់លាស់ថាបានក៏រិតណាទេ ចាំគណបក្សនយោបាយចុះបញ្ជីរួចរាល់សិន ឯកឧត្តមយល់ស្របនិងចំណុចនេះ ។ តាមគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញថា ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស គប្បីយកគំនិតធ្វើយ៉ាងណាឱ្យមានគណបក្សច្រើន ។ ដំបូងឡើយយើងមានគណបក្ស ៥៤រួចមកធ្លាក់មក ៣០ រួចមកមានត្រឹម ២៤ ឯកឧត្តមគិតថាមិនមានលើសពី ១០ទេដែលរស់នៅនាបច្ចុប្បន្ន ។ យើងមានការស្ញប់ស្ញែងណាស់ ចំពោះគណបក្សនយោបាយដែលមិនទាន់មានមធ្យោបាយ ឬចង់រស់តែរស់មិនបាន ព្រោះមានការខ្វះខាត ។

ចំពោះការកំណត់ពេលវេលាក្នុងការនិយាយ បើសិនជាមានគោលការណ៍លើកទឹកចិត្តជាការប្រសើរ បើគណបក្សមួយមានពេល ១៥នាទី យ៉ាងតិចឱ្យបាន ១០ នាទី ព្រោះយើងត្រូវការមានការនិយាយគោរពទៅអង្គប្រជុំ ឬព្រះមហាក្សត្រ ។ គ្រាន់តែគោរពយើងអាចចំណាយពេល ២នាទី

ទៅហើយ សូមឱ្យយើងឱ្យតម្លៃទៅលើក្រមសីលធម៌ផង ព្រោះជាតិយើងមានព្រះមហាក្សត្រ មានព្រះសង្ឃ ។ ដូច្នេះសូមកុំឱ្យចាត់ពេលវេលាគោរព ចូលទៅក្នុងសាច់រឿង ។

គណបក្សនយោបាយខ្លះថ្មីត្បិតតែតូចមែន ប៉ុន្តែខ្លួនយល់ថាធ្វើនេះមិនមែនសំរាប់ប្រយោជន៍បុគ្គលទេ គឺធ្វើសំរាប់រក្សានូវគោលនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ឯកឧត្តមខ្លាចតែប្រទេសយើងក្លាយជាប្រទេសដែលមានបក្សតែមួយទៅវិញ ។ នៅឆ្នាំ ១៩៧០ គេលើកទឹកចិត្តឱ្យមានពហុបក្សឡើងវិញ ប៉ុន្តែដល់គណបក្សមួយខ្លាំងពេក គណបក្សពីរទៀតរលាយបាត់ ។ ដូច្នេះយើងគួរតែគិតគូរឱ្យមានតុល្យភាពរវាងគណបក្សទាំងអស់ ធ្វើបែបនេះលទ្ធិប្រជាធិបតេយ្យនឹងមានបរិបូរណ៍ បើសិនជាគ្មានគឺនាំឱ្យលទ្ធិប្រជាធិបតេយ្យធ្លាក់ចុះ ។ ឯកឧត្តមបារម្ភថា កាលណាមានគណបក្សតែមួយយើងជៀសសង្គ្រាមមិនរួចទេ ។

**ឯកឧត្តម ទេព នីថា** បានធ្វើការបកស្រាយនូវសំណួរមួយចំនួនរបស់អង្គប្រជុំ

ទាក់ទងនិងសំណួរខាងនិកហ្វិច ចំពោះនីតិវិធីនេះ គឺសរសេរដូចនីតិវិធីដែលធ្វើការផ្សព្វផ្សាយលើកមុនដែរ ។ ទ្រង់ទ្រាយធំ គឺចង់សំដៅការរៀបចំជាក្បួនឡាន ឬមធ្យោបាយផ្សេងទៀតដើម្បីដឹកអ្នកបោះឆ្នោត ប៉ុន្តែបើជាមធ្យោបាយរួមជាគ្រួសារ គជប អាចអនុញ្ញាតឱ្យទៅជាមួយ ។ ការហែរជាក្បួនដូចជារថយន្តដឹកមនុស្សទៅបោះឆ្នោត ៣-៤ មួយខ្សែ ចំណុចនេះមិនអនុញ្ញាតទេ ។ ពីមុនក៏មានសំណូមពរឱ្យកំណត់ថាដាក់ ១០ឬ២០ នាក់ ប៉ុន្តែ គជប គិតថាបើដាក់បែបនេះដូចជាក៏រិតពេក ហើយដាក់ ១០នាក់គឺលើសពីគំរោងដែល គជប ចង់បាន ដូចនេះបានជា គជប ទុកក្នុងក៏រិតមួយ ។ ក៏រិតនេះអាចទូលាយជាង ហើយមានការបកស្រាយមួយចំនួនដែលអាចជៀសវាងទំនាស់បាន ។ បើដាក់ ១០នាក់ ស្រាប់តែដល់ ១១ នាក់ ទាំងអ្នកបើកបរ ចំណុចនេះបើមានការប្តឹងដែរក៏ជាការលំបាកដែរ ។ បញ្ហាបែបនេះភាគច្រើនគណបក្ស មានគ្រួសារ អ្នកដែលនៅជិតខាងដែលមាន និន្នាការនយោបាយមួយចំនួនបានធ្វើរួចហើយមិនអាចហាមឃាត់បានទេ ។

ឯកឧត្តមបានលើកជាឧទាហរណ៍ថា ការិយាល័យបោះឆ្នោត គជប កំណត់នៅត្រើយម្ខាងនៃស្ទឹង ប៉ុន្តែនៅឆ្នាំ ២០០៣ ពេលទឹកជន់មកហូរកាត់ព្រែកមួយនៅក្នុងភូមិ ជាមធ្យោបាយ គជប សុំកាណូតរបស់ អាជ្ញាធរទៅដឹកប្រជាពលរដ្ឋមកបោះឆ្នោត ហើយប្រើមធ្យោបាយរបស់រដ្ឋទៅដឹកមនុស្សយកមកបោះឆ្នោត ដែលជាចំណុចមួយមានការហាមឃាត់ ។ នេះជាបញ្ហា តែ គជប បានជូនព័ត៌មានមុន ។ ការក៏រិតណាមួយជាក់ស្តែងលម្អិតពេក នាំឱ្យចងវិញ ហើយពិបាកក្នុងការអនុវត្តន៍ ។ ចំពោះរថយន្តដូចដែលបានបញ្ជាក់ហើយថា អ្វីដែលមិនមានកំណត់នៅ ក្នុងនីតិវិធី គឺយើងមិនហាមទេ ។ ឧទាហរណ៍ ឡានផ្លាកព្រឹទ្ធសភា រដ្ឋសភា គឺគាត់តំណាងគណបក្សនយោបាយស្រេចរួចហើយ មិនអាចទៅហាមបានទេ ហាមបានតែមធ្យោបាយរបស់រដ្ឋ ។

ភ្ជាប់ជាមួយនិងបញ្ហានេះ ឯកឧត្តមបានឆ្លើយភ្ជាប់ជាមួយនិងខាង IRI ដែលបានលើកឡើងថាសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ធ្វើការអប់រំប្រជាពលរដ្ឋអំពីការបោះឆ្នោត គឺ គជប មិនមានការហាមឃាត់ទេ ហើយមិនបាច់សុំទៅ គជប ទេ អាចជូនព័ត៌មានទៅគណៈកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោតនៅមូលដ្ឋាន ។ លើកលែងតែសកម្មភាពផ្សេងៗរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយមិនមែនជាការបោះឆ្នោត ចំណុចនេះទើបអនុវត្តន៍តាមនីតិវិធីដែលធ្លាប់ធ្វើ ។

ដោយឡែកទាក់ទងនិងការរៀបចំកម្មវិធីស្មើភាពដល់គណបក្សនយោបាយ ជាពិសេសដល់បេក្ខជន កន្លងមក គជប ធ្លាប់ធ្វើការណែនាំទាក់ទងនិងនីតិវិធីនៃការរៀបចំកម្មវិធីស្មើភាព ។ គជប នឹងចេញនីតិវិធីណែនាំឱ្យច្បាស់ថែមទៀតពីលើនីតិវិធីដែលមានស្រាប់ ដើម្បីឱ្យអង្គការមិនមែនរដ្ឋាភិបាលរៀបចំកម្មវិធីនេះអនុវត្តន៍ ។ បើពិនិត្យមើលនីតិវិធីថាក្នុងការអប់រំអ្នកបោះឆ្នោត ទោះបីរៀបចំការប្រជុំជាមួយគណបក្សនយោបាយក្តី តែគោលដៅធំបំផុត គឺអប់រំអ្នកបោះឆ្នោត ។ ដូចនេះការអប់រំអ្នកបោះឆ្នោតអង្គការមិនមែនរដ្ឋាភិបាលអាចឆ្លងខ្លឹមសារជាមួយ គជប ក៏បាន មិនឆ្លងក៏បាន ។ តែក្នុងករណីដែលធ្វើមិនត្រឹមត្រូវតាមច្បាប់ គជប មានសិទ្ធិពិន័យ ។

ជាក់ស្តែងក្នុងការរៀបចំកម្មវិធីស្មើភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយ ។ កន្លងមកបើសិនជាជូនព័ត៌មានបានមុនមួយសប្តាហ៍គឺល្អណាស់ហើយចំពោះគណបក្សនយោបាយដែលចូលរួម ប៉ុន្តែមានកន្លែងខ្លះជូនព័ត៌មានមិនបានមុនមួយសប្តាហ៍ទេ គឺសូមឱ្យ គជប អន្តរាគមន៍ថែមទៀត ។ ដោយសារចង់ផ្តល់ឱកាសឱ្យគណបក្សនយោបាយ គជប ក៏ជួយអន្តរាគមន៍បន្ថែមទៅគណបក្ស ពេលខ្លះក៏ត្រូវទទួលការរិះគន់ពីគណបក្សនយោបាយ ព្រោះពេលវេលាខ្លីណាស់ដើម្បីរៀបចំបញ្ជូនមន្ត្រីតំណាងមកធ្វើការពិភាក្សា ។ ហើយការពិភាក្សាតុមូល ការឆ្លើយនិងសំណួររបស់បេក្ខជនម្នាក់ៗ ក៏ទាមទារអ្នកមានសមត្ថភាព និងការរៀបចំខ្លួនឱ្យបានល្អដែរ ។ ប្រសិនបើការពិភាក្សានេះមានការគ្រប់គ្រងមួយមិនបានល្អ ការផ្តល់ឱកាសមិនបានស្មើភាព បញ្ហានេះក៏នាំឱ្យមានការលំអៀង ជាលទ្ធផលក៏មិនអាចទទួលបានជោគជ័យដែរ ។

ក្នុងការផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ទាក់ទងនិងសកម្មភាពរបស់គណបក្សនយោបាយ វាមិនមែនមានបញ្ហាតែនៅប្រទេសយើងទេ នៅប្រទេសមហាអំណាចណាក៏អញ្ចឹងដែរ គឺមានការលំបាកក្នុងការបែងចែកពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត ឬពេលមិនបោះឆ្នោត ។ ធម្មតាប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ តែងផ្សព្វផ្សាយពីសកម្មភាពរបស់រដ្ឋ ។ ដោយឡែកប្រទេសមួយចំនួនដែលមានប្រព័ន្ធផ្សព្វផ្សាយដែលលំអៀងទៅលើគណបក្ស ក៏គេធ្វើការផ្សព្វផ្សាយតាមរបៀបលំអៀងគណបក្ស ។ អញ្ចឹងយុទ្ធនាការរបស់ គជប ក្នុងការគ្រប់គ្រងការងារឃោសនាបោះឆ្នោត មើលក្នុងច្បាប់ គឺអនុញ្ញាតឱ្យ គជប ធ្វើការក្នុងរយៈពេល ១៥ថ្ងៃនៃការឃោសនាបោះឆ្នោត ដែលគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។

ដោយឡែកប្រព័ន្ធផ្សព្វផ្សាយឯកជនយើងគ្រាន់តែទៅក្រសួងព័ត៌មានដើម្បីណែនាំយ៉ាងណា កុំឱ្យប្រព័ន្ធនោះធ្វើការឃោសនា ឬផ្សាយព័ត៌មានដែលលំអៀង ។ គជប ក៏បានស្នើក្រៅផ្លូវការទៅប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋរួចហើយ ដើម្បីកែសំរួលការផ្សព្វផ្សាយមួយចំនួននៅមុនពេលដែលដឹងថាបញ្ជីគណបក្សថាជាគណបក្សណាខ្លះដែលឈរឈ្មោះ ។ ពេលដែលដឹងថាគណបក្សណាឈរឈ្មោះខ្លះហើយ យើងនិងរិតបន្តឹងថែមមួយជំហ៊ានទៀត ព្រោះយើងពិបាកបែងចែងថា ពេលណាបោះឆ្នោត ពេលណាមិនបោះឆ្នោត ហើយរូបភាពណាមួយជាសកម្មភាពរបស់គណបក្សនយោបាយកាន់អំណាច រូបភាពណាមួយជារបស់រដ្ឋាភិបាល ព្រោះមនុស្សតែមួយ ។ ធម្មតាគណបក្សកាន់អំណាចដែលឈ្នះហើយ តែងតែឆ្លៀតយកចំណេញនៅពេលដែលខ្លួនកាន់អំណាចទៅលើប្រព័ន្ធផ្សព្វផ្សាយ ឬរូបភាពផ្សេងទៀត ។ ប៉ុន្តែការឆ្លៀតនេះវាស្របច្បាប់ ហើយការគ្រប់គ្រងរបស់យើងមិនអាចបំពានលើច្បាប់បានទេ ។ បញ្ហានេះ គជប និងខិតខំថែមទៀតនៅពេលដែលដឹងថាគណបក្សណាឈរឈ្មោះ ហើយ គជប និងសុំទៅប្រព័ន្ធ ផ្សព្វផ្សាយរបស់រដ្ឋ និងក្រសួងដែលពាក់ព័ន្ធ ដើម្បីរិតការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជនឱ្យមានលក្ខណៈវិជ្ជមានសំរាប់គណបក្សនយោបាយទាំង អស់ដែលឈរឈ្មោះ ។

ទាក់ទងនិងចំណុចដែលបានលើកឡើងដោយគណបក្សសមរង្ស៊ី ឯកឧត្តមបានមានប្រសាសន៍ថា ការផ្សព្វផ្សាយរបស់ គជប អំពីការអនុវត្តន៍បែបបទហិរញ្ញវត្ថុក្នុងការបញ្ជាទិញ គឺ គជប គោរពតាមច្បាប់ហិរញ្ញវត្ថុ គោរពតាមនីតិវិធីនៃ គជប ។ បើចាយលុយប្រទេសណា យើងអនុវត្តតាមនីតិវិធីប្រទេសនោះតម្រូវ ។ ចំពោះនីតិវិធីនៃការដេញថ្លៃ ឬពិគ្រោះថ្លៃរបស់ គជប កន្លងមក គជប សុំសិទ្ធិពីក្រសួងហិរញ្ញវត្ថុក្នុងការធ្វើការពិគ្រោះថ្លៃ ដោយមិនធ្វើការដេញថ្លៃ ព្រោះការធ្វើការដេញថ្លៃត្រូវមានការធានាពីថវិការរបស់រដ្ឋមួយសិន ។ ឧទាហរណ៍ថា ទិញកៅអីមួយតំលៃ ៥ដុល្លា អញ្ចឹងរដ្ឋចេញធានាឱ្យមក ៥ដុល្លាសិន ទើបបានយកទៅផ្សព្វផ្សាយចំនួនកន្លះខែ ហើយបានយកមកដេញថ្លៃ បើកាលណាផ្សព្វផ្សាយហើយអ្នកមកដាក់ពាក្យដេញថ្លៃមិនគ្រប់ចំនួនត្រូវផ្សព្វផ្សាយម្តងទៀត ។ ករណីបែបនេះមកធ្វើការងារបោះឆ្នោតមិនបានទេ អញ្ចឹង គជប សុំការពិគ្រោះថ្លៃ គឺយើងសុំគំរោង ចំណាយទៅក្រសួងហិរញ្ញវត្ថុ ហើយក្រសួងកំណត់គំរោងចំណាយថវិការបានហើយ យើងចុះសារព័ត៌មានប្រកាស ៥ថ្ងៃ បិទផ្សាយនៅ គជប ក្រុមហ៊ុនមកដាក់ពាក្យហើយដល់ថ្ងៃបើកកញ្ចប់នេះ យើងហៅក្រុមហ៊ុនដែលដាក់ម្នាក់ម្តង១មកតថ្លៃគ្នា ហើយអ្នកណាទាបជាងគេយើងយកក្រុមហ៊ុននោះ ។ ក៏ប៉ុន្តែមិនមែនទាបជាងគេ យើងយកទាំងអស់ទេយើងត្រូវមើល ព្រោះយើងមានបទពិសោធន៍បោះឆ្នោតច្រើនលើកហើយ ក្រុមហ៊ុនខ្លះគ្រាន់តែមកក្រឡុកថ្លៃទេ ពុំមានសមត្ថភាពធ្វើការងារឱ្យបានទេ ។

ទាក់ទងនិងគំរូសន្លឹកឆ្នោត គជប បានសំរេចរួចហើយ បើសិនជាគណបក្សច្រើន យើងធ្វើទំរង់វែងជាងក្រដាក់ $A_4$ ហើយយើងគូសដាច់តែម្តង ហើយអ្នកគូសសន្លឹកឆ្នោតអាចគូសក្នុងប្រឡោះវែងកន្លែងណាក៏បាន ឱ្យតែនៅក្នុងគណបក្សមួយ ។ មុនធ្វើសន្លឹកឆ្នោតនេះ គជប នឹងយករូប Logo គណបក្ស ឈ្មោះពេញ ឈ្មោះជាអក្សរកាត់ យកទៅស្កេនដាក់ចូលក្នុងសន្លឹកឆ្នោត បន្ទាប់មកហៅសាម៉ីគណបក្សទៅមើលថាតើពេញចិត្តទេរូបហ្នឹង បើយល់ព្រមមានការចុះហត្ថលេខា ថាព្រមទទួលយករូបហ្នឹងហើយ ។ ពេលបានចុះហត្ថលេខាគ្រប់គណបក្ស គជប នឹងធ្វើការបោះពុម្ព ។

ចំពោះការសុំច្បាប់ឃោសនា យើងគួរងាកទៅមើលច្បាប់ និងនីតិវិធីនៃការបោះឆ្នោត ព្រោះនៅក្នុងការឃោសនាបោះឆ្នោត គណបក្សមិនបាច់សុំច្បាប់អ្នកណាទេ នៅក្នុងឃុំសង្កាត់ហ្នឹងជូនដំណឹងទៅគណៈកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោត ហើយគេនិងសំរបសំរួលឱ្យនៅទីកន្លែងតាមលំដាប់មុនក្រោយ ។ យើងមិនបាច់សុំច្បាប់ គជប ឬក្រសួងមហាផ្ទៃទេ លើកលែងតែក្រៅពីរយៈពេលនៃការឃោសនាបោះឆ្នោត ទើបគណបក្សធ្វើសកម្មភាពអនុវត្តន៍តាមច្បាប់ស្តីពីគណបក្សនយោបាយ ។

ចំពោះសំណួរទាក់ទងនិងរឿងច្បាប់ ដោយសារឯកសារនេះស្រង់ចេញពីនីតិវិធីនៃ គជប ដែលគ្រាន់តែស្រង់ត្រង់ចំណុចច្បាប់ទាក់ទងនិងការឃោសនាបោះឆ្នោត ។ ដោយឡែកខាងទោសបញ្ញត្តិយើងមិនបានស្រង់មកដាក់ តែឯកឧត្តមបានជំរាបជារួមថា ការពិន័យដល់គណបក្សនយោបាយដែលប្រព្រឹត្តិបំពានលើការឃោសនាបោះឆ្នោត **ទី១** អាចពិន័យជាប្រាក់ **ទី២** អាចដកបេក្ខភាពមិនឱ្យឈរឈ្មោះនៅក្នុងការបោះឆ្នោត ។

រហូតមកដល់ពេលនេះ គជប មិនទាន់បានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅឡើយទេ យើងនឹងចុះនៅថ្ងៃ ១-៣ ខែមករា អញ្ចឹង គជប មិនទាន់ដឹងថាមានគណបក្សប៉ុន្មានឈរឈ្មោះទេ ។ ឯកឧត្តមបានរំលឹកថា នៅឆ្នាំ ២០០២ បោះឆ្នោតឃុំមានគណបក្ស ៨ឈរឈ្មោះ ក្នុងនោះមានគណបក្សស្រ្តីកម្ពុជា ឈរឈ្មោះតែមួយឃុំ នៅកំពង់ស្ពឺ មានបេក្ខជន ១៨នាក់ ។ ចំពោះបញ្ហាស្ត្រី ដោយមានការលើកច្រើនមកហើយ តែ គជប គ្រាន់តែលើកចិត្តទេ ការដាក់បេក្ខជនជានារី គឺគណបក្សនយោបាយ ។

ទាក់ទងនិងយុវជនដែលធ្វើការជាមួយ UNDPគឺ គជប មិនមានលក្ខខ័ណ្ឌក្នុងការជ្រើសរើសទេ គឺ UNDPជាអ្នកធ្វើ ដោយគ្រាន់តែប្រគល់បញ្ជីឈ្មោះ ដែលឈ្មោះនោះគេរាយការណ៍ស្រេចតែម្តង ថានៅភូមិណា ឃុំណា គជប គ្រាន់តែបញ្ចូលឈ្មោះទៅក្រុមដែល គជប ចាត់តាំងឡើង ។ ហើយ NGO ដែលធ្វើការគឺទទួលបានថវិការឧបត្ថម្ភពី UNDP ។

**លោក ឱក សេរី សោភក្តិ៍** បានមានប្រសាសន៍ថានៅក្នុងបញ្ហាយុទ្ធនាការឃោសនាបោះឆ្នោត មានចំណុចសំខាន់ ៤

**ទី១** បើសិនជាមានករណីឃាតកម្មកើតឡើង នៅក្នុងរដូវឃោសនាបោះឆ្នោត ទោះបីមិនមែនជានយោបាយ ក៏ត្រូវតែមានលក្ខណៈនយោបាយដែរ ។ បញ្ហានេះអាស្រ័យលើអាជ្ញាធរ តើប្រញាប់រកឃើញនូវជនឧក្រិដ្ឋ ហើយពិន័យផ្តន្ទាទោសឱ្យបានលឿនប៉ុណ្ណា បើកាន់តែយូរ កាន់តែមានបញ្ហាឡើង ។

**ទី២** តាមដែលបានធ្វើឧបសែលប្រ៊មនៅតាមខេត្តទាំង ១៩ នៅពេលដែល PECសំរបសំរួលប្រជុំប្រចាំសប្តាហ៍ ហើយប្រជុំមានលក្ខណៈពិសេសរវាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល អ្នកសង្កេតការនានា នៅពេលដែលគាត់ម៉ឺងម៉ាត់នៅក្នុងការប្រជុំ គឺបញ្ហាអាចដោះស្រាយបានភ្លាមៗ ។ ការគ្រប់គ្រងស្ថាក់ការណិ ដូចជាឧបទ្ទវហេតុដែលកើតឡើងនៅខេត្តកំពត នៅក្រុងកែប កាលពីឆ្នាំ ២០០៣ ឯកឧត្តម គៀង វ៉ា ដែលជាតំណាងគណបក្សសមរង្ស៊ីបានសំរេចភ្លាមៗ ដើម្បីបញ្ចៀសក្បួនដង្ហែរកុំឱ្យប៉ះគ្នាជាមួយគណបក្សប្រជាជន ព្រោះមានមនុស្សរាប់ពាន់នាក់ បើសិនជាប៉ះប្រាកដជាកើតមានអំពើហិង្សា ។ ដូច្នេះការសំរបសំរួល ការអត់ធ្មត់ និងការត្រួតត្រាអារម្មណ៏របស់អ្នកតំណាងគណបក្សនយោបាយទៅតាមមណ្ឌលនានាជាការសំខាន់ណាស់ ដើម្បីបញ្ចៀសនូវការប៉ះទង្គិច ។

**ទី៣** បើសិនជាការប្រជុំប្រចាំសហប្តាហ៏យល់ច្បាស់គ្រប់គ្នា ព្រមគ្រប់គ្នាទៅលើកាលវិភាគការបែងចែកទីកន្លែង ពេលវេលាដែលត្រូវធ្វើការឃោសនា ដោយគោរពទៅតាមនីតិវិធី និងបទបញ្ញាតិរបស់ គជប និងគោរពទៅតាមក្រមសីលធមិរបស់គណបក្សនយោបាយ និងការឃោសនា យើងគិតថាអាចនិងគ្រប់គ្រងស្ថានការណ៍នេះបាន ។

**ទី៤** កម្មវិធីស្មើភាពមានសារៈសំខាន់ លោកសង្ឃឹមថា គជប នឹងសំរេចនៅក្នុងរឿងនេះឱ្យមានលក្ខណៈស្មើភាពមែនទែន លោកយល់ស្រប ទៅនិងវាគ្មិនដែលបានលើកឡើងថា តូចក្តី ធំក្តី នៅក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត នៅចំពោះមុខច្បាប់សុំឱ្យ គេបំពេញបែបបទស្មើៗគ្នា ។ ដោយគណបក្សធំមានមធ្យោបាយធំរួចហើយ បើសិនជាកាត់ច្រិបទៅលើគណបក្សតូចនៅក្នុងពេល ១៥ថ្ងៃទៀត គឺកាន់តែយ៉ាប់ហើយ ។